ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២៤

# របស់ អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប

រៀបចំដោយ៖ អាជ្ញាធរទន្លេសាប

សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប

ខែមករា ឆ្នាំ ២០២៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

TONLE SAP AUTHORITY

**អាជ្ញាធរទន្លេសាប**

លេខ :...០០៦........អទស

ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា គ.ស. ២០២៤

**ជម្រាបមក**

**ឯកឧត្តមអនុប្រធាន ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង**

**លោកទីប្រឹក្សា និងលោកប្រធាននាយកដ្ឋានក្រោមឱវាទ**

**អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប**

**កម្មវត្ថុ** ៖ ការដាក់ឲ្យអនុវត្តន៍ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២៤ របស់អាជ្ញាធរទន្លេសាប ។

**យោង** ៖ ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់អាជ្ញាធរទន្លេសាប ។

**ជូនភ្ជាប់** ៖ ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២៤ របស់អាជ្ញាធរទន្លេសាប ។

ន័យដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកទីប្រឹក្សា និងលោកប្រធាននាយកដ្ឋាន ជ្រាបថា ៖ ក្នុងស្មារតីយកចិត្តទុកដាក់ជម្រុញនូវកិច្ចការការពារធនធានធម្មជាតិ និងជីវចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយចីរភាព ដើម្បីចូលរួមលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ។

អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប បានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២៤ ដើម្បីជម្រុញប្រសិទ្ធភាពការអនុវត្តផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាបឆ្នាំ ២០២៤-២០២៨ ឲ្យទទួលបានជោគជ័យ និងបន្តពង្រឹងការអនុវត្តបេសកកម្មស្នូលរបស់អាជ្ញាធរទន្លេសាប ក្នុងការសិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីសក្ដានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិ ស្របតាមអាណត្តិការងារសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយចីរភាព ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកទីប្រឹក្សា និងលោកប្រធាននាយកដ្ឋាន ក្រោមឱវាទ អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប អនុវត្តន៍ឲ្យបានល្អប្រសើរ និងមានប្រសិទ្ធភាព ។

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**ថោ-ជេដ្ឋា**

# បុព្វកថា

បឹងទន្លេសាប គឺជាបឹងទឹកសាបធម្មជាតិធំជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងជាមរតកសម្បត្តិធនធានធម្មជាតិរបស់ប្រទេសកម្ពុជា ដែលមិនអាចកាត់ថ្លៃបានលើផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ។ បឹងទន្លេសាប មានទំនាក់ទំនងជាមួយទន្លេមេគង្គ តាមរយៈទន្លេសាប ដែលជាប្រព័ន្ធផ្លូវទឹកមួយដ៏សំខាន់ ក្នុងការទទួលឥទ្ធិពលរបបទឹកពីទន្លេមេគង្គនៅរដូវវស្សា និងហូរចាក់មកទន្លេមេគង្គវិញនៅរដូវប្រាំង បង្កើតបានជាបាតុភូតដ៏កម្រមួយក្នុងពិភពលោក ។ បឹងទន្លេសាបរួមជាមួយប្រព័ន្ធអេកូឡូស៊ីធម្មជាតិប្រកបដោយសក្តានុពលក្នុងការផ្តល់ប្រភពប្រូតេអ៊ីនបាន ៦០% សម្រាប់ប្រជាជនកម្ពុជា និងជាទីកន្លែងជម្រកដ៏សំខាន់នៃជីវចម្រុះគ្រប់ប្រភេទ ដែលអាចជួយទ្រទ្រង់ដល់ផលិតភាព ត្រី ស្រូវ កសិកម្ម និងធនធានដីសើមដ៏ច្រើន ។ ជាពិសេស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ដល់សន្តិសុខស្បៀង និងផ្គត់ផ្គង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស ។

បច្ចុប្បន្នសម្ពាធនៃការអភិវឌ្ឍ កំណើនប្រជាជន វិសមភាពសិទ្ធិទទួលផល និងភាពក្រីក្ររបស់ប្រជាជនរស់នៅពឹងផ្អែកទាំងស្រុងលើធនធានធម្មជាតិ បាននឹងកំពុងតែធ្វើឲ្យប្រព័ន្ធអេកូឡូស៊ីរបស់បឹងទន្លេសាប ស្ថិតក្នុងភាពប្រឈមដោយទទួលរងនូវការគំរាមកំហែងកាន់តែធ្ងន់ធ្ងរមកលើសុខុមាលភាពរបស់បឹងបរិស្ថាន ជីវចម្រុះ និងធនធានធម្មជាតិបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ដូចជា ៖ ការប្រើប្រាស់បច្ចេកវិទ្យាខុសបទដ្ឋានបច្ចេកទេស ការទន្ទ្រានដីព្រៃលិចទឹកពង្រីកផ្ទៃដីកសិកម្ម ការប្រើប្រាស់ជីគីមី ថ្នាំសម្លាប់សត្វល្អិត ការធ្វើអាជីវកម្មហួសកម្រិតមកលើធនធានជលផល ការសាងសង់ទំនប់ស្ទាក់ទឹក ការសាងសង់វារីអគ្គិសនី និងបម្រែបម្រួលអាកាសធាតុជាដើម ។

ដោយមើលឃើញពីសារៈសំខាន់នៃបឹងទន្លេសាប និងដើម្បីចូលរួមចំណែកក្នុងកិច្ចការការពារធនធានធម្មជាតិ និងជីវចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសការធានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានដ៏កម្រនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយនិរន្តរភាព អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប បានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ២០២៤ សម្រាប់គាំទ្រផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ ដោយមានការចូលរួមរៀបចំដោយ នាយកដ្ឋាន ការិយាល័យ និងមន្ត្រីបច្ចេកទេសក្រោមឱវាទ ។

អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប សូមដាក់ចេញនូវ **ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២៤** ដែលជាឧបករណ៍ជួយតម្រង់ទិសសម្រាប់ឲ្យថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប យកទៅអនុវត្តជាសកម្មភាពការងារ ដើម្បីឈានទៅសម្រេចគោលដៅតាមការរំពឹងទុក ដូចបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែ បុស្ស ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២៤

**អគ្គលេខាធិការ**

**សេរ.គឹមសាន្ត**

# មាតិកា

**បុព្វកថា** ....................................................................................................

I. **សេចក្តីផ្តើម** ..................................................................................... 1

II. **អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប**. ......................................................... 2

២.១. តួនាទីភារកិច្ច ........................................................................... 2

២.២. រចនាសម្ព័ន្ធ ........................................................................... 3

២.៣. ធនធានមនុស្ស ........................................................................... 3

III. **វឌ្ឍនភាពផែនការសកម្មភាពឆ្នាំ ២០២៣**. ......................................................... 4

៣.១. សេចក្តីផ្តើម ........................................................................... 4

៣.២. លទ្ធផលសម្រេចបាន ២០២៣ ........................................................................... 4

៣.៣. បញ្ហាប្រឈម និងកាលានុវត្តភាព ........................................................................... 6

៣.៤. សន្និដ្ឋាន និងទិសដៅការងារបន្ត ........................................................................... 8

IV. **ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨** ......................................................... 11

V. **ផែនការសកម្មភាពឆ្នាំ ២០២៤**. ......................................................... 13

៤.១. សេចក្តីផ្តើម ........................................................................... 13

៤.២. តារាងម៉ាទ្រិចផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ ........................................................ 14

៤.៣. តារាងម៉ាទ្រិចសូចនាករ និងលទ្ធផលរំពឹងទុកសកម្មភាពការងារប្រចាំឆ្នាំ ២០២៤ ....... 32

៤.៤. ធនធានហិរញ្ញវត្ថុអនុវត្តសកម្មភាពការងារប្រចាំឆ្នាំ ២០២៤ ....................................... 51

VI. **ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ** ......................................................... 51

VII. **សេចក្តីសន្និដ្ឋាន** ......................................................... 52

VIII. **ឧបសម្ព័ន្ធ** ......................................................... 53

ឧបសម្ព័ន្ធទី១ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប .... 53

ឧបសម្ព័ន្ធទី២ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ស្តីពីការកែសម្រួល មាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/ ៧០៥ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប................................ 60

ឧបសម្ព័ន្ធទី៣ អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ........................................ 65

ឧបសម្ព័ន្ធទី៤ ប្រកាសលេខ ០២៥ អ.ទ.ស ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ការិយាល័យ ចំណុះបណ្ដានាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ....... 70

ឧបសម្ព័ន្ធទី៥ អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ស្តីពីការកំណត់ដែនព្រៃលិចទឹក ចំនួន ៦៤៧.៤០៦ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប.................... 77

# I. សេចក្តីផ្តើម

អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ត្រូវបានប្រកាសដាក់ឲ្យប្រើប្រាស់កាលពីថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៩ មានគោលដៅកំណត់ពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ។ ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃដំណើរការការងាររបស់អង្គភាព នាយកដ្ឋានជំនាញទាំង ៤ ស្ថិតក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប រួមមាន នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ, នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ, នាយកដ្ឋានធនធានធម្មជាតិ និងនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការបំពេញមុខងារជាសេនាធិការឲ្យអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដែលបានកំណត់ពីតួនាទី និងភារកិច្ចច្បាស់លាស់ដូចមានចែងក្នុងអនុក្រឹត្យ ព្រមទាំងអមដោយការិយាល័យចំនួន ១៤ ចំណុះឲ្យនាយកដ្ឋាន ដូចបានកំណត់នៅក្នុងប្រកាសលេខ ០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះបណ្តាលនាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ។

ផ្តើមចេញពីគោលដៅ និងសកម្មភាពយុទ្ធសាស្ត្រ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប សម្រាប់រយៈពេល ៥ ឆ្នាំ (២០២៤-២០២៨) និងតាមរយៈនៃបេសកកម្មការងារ តួនាទី និងភារកិច្ចរបស់អាជ្ញាធរទន្លេសាប ដែលជាសេនាធិការឲ្យរាជរដ្ឋាភិបាល ។ អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប បានធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព ២០២៣ និងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ ដោយបានកំណត់នូវសកម្មភាពការងារលម្អិត ដែលត្រូវអនុវត្តប្រចាំឆ្នាំ ២០២៤ ទៅតាមគោលដៅយុទ្ធសាស្ត្រទាំង ៥ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប រួមមាន ៖ (១). អភិវឌ្ឍន៍ព័ត៌មាន និងទិន្នន័យឲ្យកាន់តែប្រសើរឡើង អំពីតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ, (២). លើកកម្ពស់ការយល់ដឹង អប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាល, (៣). ពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ, (៤). លើកកម្ពស់សមត្ថភាពការងារ និងពង្រឹងការគ្រប់គ្រងស្ថាប័ន, (៥). លើកកម្ពស់ និងអភិវឌ្ឍន៍ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានឌីជីថល ។

ផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ត្រូវបានរៀបចំឡើងដោយការប្រមូលផ្តុំរាល់គំនិតយោបល់ ដែលជាធាតុចូលដ៏មានសារៈសំខាន់ តាមរយៈនៃការចូលរួមពិភាក្សា និងកែតម្រូវពីថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប នាយកដ្ឋានជំនាញទាំង ៤ និងការិយាល័យចំណុះទាំង ១៤ ក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដើម្បីប្រើប្រាស់ជាឧបករណ៍ ក្នុងការចូលរួមលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់អាជ្ញាធរទន្លេសាប និងគាំទ្រដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ ឲ្យបានសម្រេចជោគជ័យស្របតាមគោលដៅ និងទិសដៅនៃការរំពឹងទុក ។ម្យ៉ាងទៀត ផែនការសកម្មភាពប្រចាំឆ្នាំនេះ ក៏ជាឧបករណ៍ក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារ ផ្ទៃក្នុងរបស់មន្ត្រីទទួលបន្ទុកសកម្មភាពការងារតាមការិយាល័យ និងនាយកដ្ឋាន ដើម្បីធានាបានការអនុវត្តការងារផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ។

តាមរយៈផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប បានកំណត់ពីសកម្មភាពការងារលម្អិត និងលទ្ធផលរំពឹងទុកក៏ដូចជា តាមរយៈសូចនាករលទ្ធផលប្រចាំឆ្នាំ និង

ការបែងចែកការអនុវត្តទទួលខុសត្រូវតាមការិយាល័យ នៃនាយកដ្ឋាននីមួយៗ ព្រមទាំងកំណត់នូវមន្ត្រីទទួលបន្ទុកជាក់លាក់ តាមសកម្មភាពសម្រាប់អនុវត្ត ដែលមានកំណត់នៅក្នុងទម្រង់តាមដានត្រួតពិនិត្យ និងវាយតម្លៃជាច់ដោយឡែក ។ ផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ នឹងក្លាយជាឯកសារគោល សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប សម្រាប់ប្រើប្រាស់ក្នុងការបំពេញមុខងារតួនាទី និងភារកិច្ច របស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។

## II. អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប

### ២.១. តួនាទីភារកិច្ច

ជាមួយនឹងបេសកកម្មការងារ និងតួនាទីភារកិច្ចស្នូលក្នុងការទទួលខុសត្រូវ ចំពោះមុខរាជរដ្ឋាភិបាល អាជ្ញាធរទន្លេសាប បានរៀបចំបង្កើតឡើងនូវ អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដូចមានកំណត់ក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ១៦៦ អនក្របក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ចែងទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាងក្រសួងស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។

យោងតាមមាត្រា ២ ជំពូកទី ២ នៃអនុក្រឹត្យ ដែលចែងពីតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប មានដូចខាងក្រោម ៖

- ទទួលបន្ទុកដឹកនាំ ចាត់ចែង និងសម្របសម្រួលរាល់សកម្មភាពការងារប្រចាំថ្ងៃរបស់អាជ្ញាធរទន្លេសាប
- សិក្សាស្រាវជ្រាវ អំពីសក្តានុពលធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដាន លើការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ និងវិភាគនូវរាល់ព័ត៌មាន និងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រចំពោះមុខ និងយូរអង្វែង ជូនរាជរដ្ឋាភិបាល ក្នុងការកំណត់ទីតាំងគោលដៅបម្រើដល់កិច្ចអភិវឌ្ឍន៍ និងអភិរក្ស
- រៀបចំគោលនយោបាយ ទស្សនវិស័យ បេសកកម្មរបស់អាជ្ញាធរទន្លេសាប
- សម្របសម្រួល និងសហការជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពទាក់ទងនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព
- សហការ ជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោងអភិរក្ស អភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុងតំបន់ទន្លេសាប
- រៀបចំចងក្រងឯកសារទិន្នន័យ ព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ

- ធ្វើរបាយការណ៍ប្រចាំខែ ឆមាស និងប្រចាំឆ្នាំ ជូនប្រធានអាជ្ញាធរទន្លេសាប
- អនុវត្តន៍ភារកិច្ចផ្សេងៗ ដែលប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន ។

## ២.២. រចនាសម្ព័ន្ធ

យោងតាមអនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ត្រូវបានប្រកាសដាក់ឲ្យប្រើប្រាស់កាលពីថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៩ បានកំណត់អំពីរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដោយបានបែងចែកនាយកដ្ឋានចំនួន ៤ គឺ នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ, នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ, នាយកដ្ឋានធនធានធម្មជាតិ និងនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ហើយនាយកដ្ឋាននីមួយៗមានការិយាល័យចំណុះ ដូចខាងក្រោម ៖

**ក. នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ**

- ការិយាល័យរដ្ឋបាល
- ការិយាល័យបុគ្គលិកបណ្តុះបណ្តាល
- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងសហប្រតិបត្តិការ

**ខ. នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ**

- ការិយាល័យនីតិកម្ម
- ការិយាល័យសម្របសម្រួលវិវាទ
- ការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ

**គ. នាយកដ្ឋានធនធានធម្មជាតិ**

- ការិយាល័យធនធានទឹក
- ការិយាល័យជីវចម្រុះ
- ការិយាល័យកសិកម្មចម្រុះ
- ការិយាល័យធនធានរ៉ែ

**ឃ. នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស**

- ការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ
- ការិយាល័យអភិរក្ស
- ការិយាល័យព័ត៌មានភូមិសាស្ត្រ និងផែនទី

## ២.៣. ធនធានមនុស្ស

បច្ចុប្បន្នអាជ្ញាធរទន្លេសាប មានមន្ត្រីសរុបចំនួន ១០១រូប ក្នុងនោះមានប្រុសចំនួន ៨៣រូប និងស្រីចំនួន ១៨រូប ។ មន្ត្រីអាជ្ញាធរទន្លេសាប មានកម្រិតក្រោយឧត្តមសិក្សាចំនួន ២៩រូប និង កម្រិតឧត្តម

សិក្សាចំនួន ៤៣រូប ដែលក្នុងនោះមានមន្ត្រីមុខងារសាធារណៈចំនួន ៦៦រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួន ២៩រូប។

អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប មានអគ្គលេខាធិការចំនួន ១រូប អគ្គលេខាធិការរងចំនួន ២ រូប ប្រធាននាយកដ្ឋានចំនួន ៤រូប អនុប្រធាននាយកដ្ឋានចំនួន ១០រូប ប្រធានការិយាល័យចំនួន ១៣រូប អនុការិយាល័យចំនួន ២៣រូប ។

## III. វឌ្ឍនភាពអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣

### ៣.១. សេចក្តីផ្តើម

ផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់ អាជ្ញាធរទន្លេសាប រៀបចំឡើង សម្រាប់គាំទ្រផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ របស់អាជ្ញាធរទន្លេសាប និងបានកំណត់ពីសកម្មភាពការងារអាទិភាពរបស់នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដើម្បីអនុវត្តសម្រេចនូវគោលបំណង លទ្ធផល (Outcome) និងធាតុចេញ (Output) ដោយប្រើប្រាស់នូវកញ្ចប់ថវិកាជាតិប្រចាំឆ្នាំ ២០២៣ ។

### ៣.២. លទ្ធផលសម្រេចបានឆ្នាំ ២០២៣

បន្ទាប់ពីប្រជុំពិនិត្យ និងវាយតម្លៃលទ្ធផលការអនុវត្តសកម្មភាពការងារនាចុងឆ្នាំ ២០២២ អំពីវឌ្ឍនភាពការងាររបស់អាជ្ញាធរទន្លេសាប និងទទួលបានការណែនាំចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំក្នុងការកំណត់ទិសដៅការងារអនុវត្តន៍បន្ត ។ អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប បានដាក់ចេញនូវផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ ដើម្បីអោយថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទ បន្តពង្រឹងប្រសិទ្ធភាពអនុវត្តន៍សកម្មភាពការងារ ដើម្បីឈានទៅសម្រេចគោលដៅតាមការរំពឹងទុក ដូចបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ របស់អាជ្ញាធរទន្លេសាបរយៈពេល ៥ឆ្នាំ ។

សកម្មភាពចុះសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានទិន្នន័យរបស់មន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសទៅតាមគម្រោងសកម្មភាពនីមួយៗ ត្រូវបានធ្វើការតាមដានពីការចុះអនុវត្តន៍ជាប្រចាំ តាមរយៈនៃការរៀបចំ និងវិភាគសរសេររបាយការណ៍ អំពីលទ្ធផលនៃការចុះអនុវត្តការងារជាក់ស្តែង ។ ជាពិសេសការប្រជុំពិនិត្យតាមដានពីលទ្ធផលនៃការអនុវត្តរយៈពេល ៦ ខែ ដើម្បីពិនិត្យលើចំណុចខ្លាំង ខ្សោយ ឧបសគ្គ និងបញ្ហាប្រឈមនានា ក្នុងការបង្កើនប្រសិទ្ធភាពបន្តអនុវត្តសកម្មភាពឲ្យទទួលបានលទ្ធផលសម្រេចតាមការរំពឹងទុក ។ សកម្មភាពចុះសិក្សាស្រាវជ្រាវតាមគម្រោងសកម្មភាពនីមួយៗ ក៏ត្រូវបានរំលេចចេញនូវលទ្ធផលតាមរយៈការរៀបចំវិភាគ និងសរសេររបាយការណ៍បច្ចេកទេស បន្ទាប់ពីបញ្ចប់ចុះអនុវត្តន៍រយៈពេល ១ ឆ្នាំ (២០២៣) ដោយឆ្លុះបញ្ចាំងពីរបកគំហើញ អំពីសក្តានុពល និងផលប៉ះពាល់មកលើបរិយាកាសសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាប ។ ក្នុងរបកគំហើញលទ្ធផលនៃការសិក្សាតាមគម្រោងសកម្មភាពនីមួយៗនេះ **អាជ្ញាធរទន្លេសាប** បានរៀបចំចងក្រងនូវ **ទស្សនាវដ្តីប្រចាំឆមាស ស្តីពីសកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប** ហើយបានរៀបចំចងក្រង **កម្រងរបាយការណ៍បច្ចេកទេស អំពីស្ថានភាពសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាបឆ្នាំ ២០២៣** ដោយធ្វើការប្រចាប់បញ្ចូលគ្នាគ្រប់របាយការណ៍បច្ចេកទេស តាមគម្រោងសកម្មភាពនីមួយៗ ។

របាយការណ៍លទ្ធផលរបកគំហើញនៃការចុះសិក្សាស្រាវជ្រាវ ក្រុមការងារមន្ត្រីបច្ចេកទេស បាន និងកំពុងប្រើប្រាស់ជាប្រយោជន៍ក្នុងការឈានទៅរៀបចំរបាយការណ៍បច្ចេកទេស គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី/គម្រោងសកម្មភាព ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងធ្វើសេចក្តីសម្រេចចិត្ត ក្នុងការកំណត់ដាក់បញ្ចូលជាក្របខ័ណ្ឌគោលនយោបាយជាតិរួម សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយចីរភាព ។

សកម្មភាពចុះសិក្សា រួមនិងលទ្ធផលការងារតាមគម្រោងសកម្មភាពនីមួយៗ មន្ត្រីថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប និងមន្ត្រីបច្ចេកទេសស្ថិតក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្កើនពង្រឹងការយល់ដឹង និងសហការចែករំលែករាល់ព័ត៌មាន ទិន្នន័យ និងចំណេះដឹង បទពិសោធន៍ពីគ្នាទៅវិញទៅមក ដើម្បីជំរុញប្រសិទ្ធភាពការងាររបស់ស្ថាប័ន ក៏ដូចជាចូលរួមគាំទ្រដល់គោលនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ជាពិសេស មន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសក្រោមឱវាទអាជ្ញាធរទន្លេសាប ក៏បានដើរតួនាទីក្នុងនាមជាអង្គភាពសម្របសម្រួល និងបានប្រើប្រាស់នូវលទ្ធផលរបកគំហើញពីការងារសិក្សាស្រាវជ្រាវធ្វើជាមូលដ្ឋានបានជាទឡ្ហីករណ៍សម្រាប់ផ្លាស់ប្តូរយោបល់ក្នុងអង្គសិក្ខាសាលា អង្គប្រជុំ និងវេទិកានានា រួមជាមួយការចែករំលែកការយល់ដឹងតាមបណ្តាញទំនាក់ទំនងគេហទំព័រ បណ្តាញសង្គម ដែលតែងតែធ្វើបច្ចុប្បន្នភាពព័ត៌មានទិន្នន័យជាប្រចាំ អំពីសកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប និងចែករំលែកបទពិសោធន៍លើកកម្ពស់ការយល់ដឹងជូនដល់ភាគីពាក់ព័ន្ធនានាទាំងក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ។ ម្យ៉ាងទៀតការលើកកម្ពស់ជំរុញការផ្សព្វផ្សាយការយល់ដឹងពីគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា មន្ត្រីថ្នាក់ដឹកនាំរបស់អាជ្ញាធរទន្លេសាប បានប្រើប្រាស់នូវចំណេះដឹង និងបទពិសោធន៍ការងារចូលរួមជាមួយក្រុមការងារស្នូលដែលជាសមាជិករបស់រាជរដ្ឋាភិបាលកម្ពុជា ចុះធ្វើការផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាននៅថ្នាក់ក្រោមជាតិ នៃខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ។

ក្នុងកិច្ចសហប្រតិបត្តិការមន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសតំណាងឲ្យអាជ្ញាធរទន្លេសាប បានធ្វើការទំនាក់ទំនង និងទទួលជួបពិភាក្សាការងារកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួង ស្ថាប័ន និងភាគីផ្តល់ជំនួយជាតិ និងអន្តរជាតិនានា (ចិន, ជប៉ុន, France, World Bank, USAID, IUCN, JICA, China-ASEAN Environmental Cooperation Center, Mekong-Lacang Center) ក្នុងការចូលរួមសមាហរណកម្មការយល់ដឹង និងចែករំលែកនូវព័ត៌មានទិន្នន័យ បង្ហាញពីលទ្ធផលសកម្មភាពសិក្សាស្រាវជ្រាវរបស់អាជ្ញាធរទន្លេសាប ក្នុងកិច្ចប្រជុំ ប្រឹក្សាយោបល់ ជាពិសេសជាមួយដៃគូគម្រោងពាក់ព័ន្ធដូចជា ៖ (១). គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន គាំទ្រថវិកាដោយភ្នាក់ងារទឹកបារាំង, (២). គម្រោងការតាមដានផលចាប់នៅខេត្តជុំវិញបឹងទន្លេសាប គាំទ្រថវិកាដោយគណៈកម្មការទន្លេមេគង្គ តាមរយៈ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (៣). គម្រោងសិក្សាគំរូបច្ចេកវិទ្យាសង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រសម្រាប់អាងទន្លេសាបកម្ពុជា គាំទ្រថវិកាក្រោមគម្រោងឡាងឆាង-មេគង្គ ។ ក្នុងនោះដែរ ក៏បានចែករំលែកនូវព័ត៌មាន និងចំណេះដឹងដល់អ្នកសិក្សាស្រាវជ្រាវ តាមរយៈវេទិកាសន្និសីទជាតិ និងអន្តរជាតិក្នុងនោះមានសិក្ខាសាលាចំនួន ៣៤ កិច្ចប្រជុំពិគ្រោះយោបល់ ១០ ។

ក្នុងដំណើរអនុវត្តន៍សកម្មភាពការងារប្រចាំឆ្នាំ ២០២៣ នេះ អាជ្ញាធរទន្លេសាប ក៏បានគិតគូរពិចារណាប្រសិទ្ធភាព នៃការចងក្រងគោលការណ៍ពិពណ៌នាអំពីតួនាទីមុខតំណែងមន្ត្រីនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាប និងបានផ្តល់ការលើកទឹកចិត្តដល់មន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស ដែលសកម្មជាមួយការងារ និងអតីតភាពការងារ ក្នុងនោះធ្វើការតែងតាំងមន្ត្រីរាជការ និងតម្លើងឋានន្តរស័ក្តិ ថ្នាក់ តាមវេន និងអតីតភាព និងតាមសញ្ញាបត្រ ។ ចំពោះការបង្កើនសមត្ថភាពចំណេះដឹងដល់មន្ត្រីរបស់អង្គភាព បានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស និងបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្នុងស្រុក មានការចូលរួមពីមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប មន្ត្រីបច្ចេកទេសគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងមន្ត្រីបច្ចេកទេសនាយកដ្ឋានជលសាស្ត្រ និងការងារទន្លេក្រសួងធនធានទឹក និងឧតុនិយម ។

ស្របជាមួយនឹងដំណើរការអនុវត្តផែនការសកម្មភាព នៅចុងឆ្នាំ ២០២៣ នៃអាណត្តិរាជរដ្ឋាភិបាលថ្មីក្នុងនីតិកាលទី ៧ រដ្ឋសភា ។ **អាជ្ញាធរទន្លេសាប** បានប្រជុំពិភាក្សា និងពិនិត្យឡើងវិញលើដំណើរការអនុវត្តផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២១-២០២៥ និងបានធ្វើបច្ចុប្បន្នភាពរៀបចំ កសាងផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ សម្រាប់រួមចំណែកលើកកម្ពស់ប្រសិទ្ធភាពអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ "បញ្ចកោណដំណាក់កាលទី ១" របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។ ដើម្បីគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ រយៈពេល ៥ឆ្នាំ អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ក៏បានបន្តពិនិត្យ អំពីវឌ្ឍនភាពការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ និងបានរៀបចំធ្វើបច្ចុប្បន្នភាព ដោយដាក់ចេញនូវផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ សំដៅពង្រឹងប្រសិទ្ធភាពការអនុវត្តសកម្មភាពការងាររបស់ស្ថាប័ន និងឈានទៅសម្រេចគោលដៅតាមការរំពឹងទុក នៅក្នុងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ។

## ៣.៣ បញ្ហាប្រឈម និងការនិរន្តរភាព

### ១. បញ្ហាប្រឈម

ជាមួយវឌ្ឍនភាពដំណើរការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ រួមជាមួយផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប ២០២១-២០២៥ **អាជ្ញាធរទន្លេសាប** ក៏បានជួបនូវចំណុចខ្វះខាត និងបញ្ហាប្រឈមមួយចំនួន រួមមាន៖

- ការផ្តល់កិច្ចសហប្រតិបត្តិការ អាជ្ញាធរដែនដី និងមន្ត្រីក្រសួង-ស្ថាប័នពាក់ព័ន្ធនៅមានកម្រិត តម្រូវឲ្យមានកិច្ចសហការពីក្រសួងស្ថាប័នជំនាញទាំងកម្រិតថ្នាក់ជាតិ ក្រោមជាតិ សហគមន៍មូលដ្ឋាន ដើម្បីជំរុញប្រសិទ្ធភាព និងល្បឿនការងារប្រកបដោយភាពជោគជ័យ
- កម្រិតគុណភាពធនធានមនុស្សនៅមានកម្រិត មិនទាន់អាចឆ្លើយតបបានពេញលេញទៅតាមសេចក្តីត្រូវការនៅឡើយ ជាពិសេសធនធានមនុស្សទៅតាមជំនាញនីមួយៗ ។ បញ្ហានេះតម្រូវឲ្យមានការជម្រុញសន្ទុះនៃការអភិវឌ្ឍធនធានមនុស្សក្នុងអាជ្ញាធរទន្លេសាប ឲ្យបានស៊ីជម្រៅទាំងបរិមាណ និងគុណភាព ដោយផ្តោតលើការកែទម្រង់កិច្ចការផ្ទៃក្នុង និងការលើក

កម្ពស់សមត្ថភាពចំណេះដឹងប្រកបដោយគុណភាព ដែលអាចឆ្លើយតបទៅនឹងការចាប់យកនូវបច្ចេកវិទ្យាថ្មីៗ និងនវានុវត្តន៍ ដើម្បីទាញយកផលប្រយោជន៍ពីការអភិវឌ្ឍបច្ចេកវិទ្យាទំនើប និងនវានុវត្តន៍ ជាពិសេសក្នុងបរិការណ៍សង្គមសេដ្ឋកិច្ចឌីជីថល

- ការពង្រឹងបណ្តាញការងារក្នុងស្ថាប័នផ្អែកលើហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យា ការប្រាស្រ័យទាក់ទង និងព័ត៌មានវិទ្យា រួមផ្សំជាមួយនឹងកញ្ចប់ថវិកាអនុវត្តនៅមានកម្រិត ក្នុងការប្រមូលចងក្រង គ្រប់គ្រងព័ត៌មាន ទិន្នន័យ តាមរយៈនៃការចុះសិក្សាស្រាវជ្រាវ ការផ្សព្វផ្សាយ និងការចែករំលែកព័ត៌មាន ចំណេះដឹង តម្រូវឲ្យមានការយកចិត្តទុកដាក់ឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីបង្កើនសមត្ថភាពគ្រប់គ្រង និងប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាថ្មីៗ ឲ្យស្របតាមបរិការណ៍សង្គមសេដ្ឋកិច្ចឌីជីថល
- សុខដុមនីយកម្មផ្ទៃក្នុងអាជ្ញាធរទន្លេសាប ទោះបីមានការកែលម្អជាបណ្តើរៗ ក៏ប៉ុន្តែនៅមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់នៅឡើយ ។ គុណភាព និងសមត្ថភាពក្នុងស្ថាប័ន គឺមានសារៈសំខាន់ ក្នុងការបង្កើនប្រសិទ្ធភាពការងារ ដែលចាំបាច់ត្រូវតែបន្តបេសកកម្មលើកកម្ពស់ និងពង្រឹងបន្ថែម ដើម្បីឲ្យដំណើរការគ្រប់គ្រងដឹកនាំការងារក្នុងស្ថាប័នប្រកបដោយភាពរឹងមាំ និងទទួលបាននូវវឌ្ឍនភាពការងារកាន់តែប្រសើរឡើង
- គម្រោងសកម្មភាពមួយចំនួន លើកឡើងក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីចុះអនុវត្តន៍នៅមិនទាន់ស៊ីជម្រៅទៅនឹងខ្លឹមសារស្របជាមួយនឹងតួនាទីភារកិច្ច និងស្ថានភាពជាក់ស្តែងដោយការវិភាគតាមលក្ខណៈ SWOT (ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងពេលវេលា ) ឬ SMART (មានជាក់លាក់ដែលអាចវាស់វែងបាន ដែលអាចសម្រេចបានមានភាពប្រាកដប្រជា និងពេលវេលាត្រឹមត្រូវ)
- បម្រែបម្រួលជាសាកលជាមួយស្ថានភាពនយោបាយ និងការកើតឡើងនៃការរីករាលដដឹកូវីដ ១៩ ក៏បានធ្វើឲ្យដំណើរការអនុវត្តសកម្មភាពប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រ មិនបានអនុវត្តបានគ្រប់ជ្រុងជ្រោយតាមការរំពឹងទុក
- កត្តាបម្រែបម្រួលអាកាសធាតុ ក៏ជាបញ្ហាមួយក្នុងចំណោមបញ្ហាផ្សេងទៀត បានធ្វើឲ្យការចុះអនុវត្តការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសក្នុងការចុះសិក្សាស្រាវជ្រាវនៅតំបន់បឹងទន្លេសាប មិនបានអនុវត្តពេញលេញ ស្របតាមផែនការការងារ ដែលតម្រូវអោយមានការយកចិត្តទុកដាក់ និងពង្រឹងប្រសិទ្ធភាពការងារបន្ថែមទៀត តាមស្ថាភាពជាក់ស្តែង ។

**២.កាលានុវត្តភាព**

ស្ថិតក្នុងស្ថានភាពនាពេលបច្ចុប្បន្ន ស្របពេលនឹងដំណើរការចូលរួមនូវការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ដោយស្មារតីយកចិត្តទុកដាក់ និងលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ ផ្តល់ឲ្យនូវកាលានុវត្តភាពសម្រាប់ **អាជ្ញាធរទន្លេសាប** ក្នុងការពង្រឹងសមត្ថភាពការងារ រួមមាន ៖

- ការបន្តលើកកម្ពស់ពង្រឹងស្ថាប័នដោយមានការកែលម្អប្រព័ន្ធការងារនៃការគ្រប់គ្រងរដ្ឋបាល ធនធានមនុស្ស ហិរញ្ញវត្ថុ និងកសាងសមត្ថភាពជំនាញដើម្បីប្រសិទ្ធភាព និងប្រសិទ្ធផល ការងារ ក្នុងការជំរុញល្បឿនការងារស្នូលរបស់ស្ថាប័ន និងសង្គមជាតិ
- ការចាប់យកបច្ចេកវិទ្យាទំនើបក្នុងបរិការណ៍សង្គមឌីជីថល ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ការងារក្នុងស្ថាប័ន ផ្អែកលើបច្ចេកវិទ្យា ការប្រាស្រ័យទាក់ទង និងព័ត៌មានវិទ្យាក្នុងការលើក កម្ពស់ប្រសិទ្ធភាពការងារលើការគ្រប់គ្រងព័ត៌មានទិន្នន័យ ការចុះសិក្សាស្រាវជ្រាវ និងការ ផ្សព្វផ្សាយ ចែករំលែកព័ត៌មានចំណេះដឹងអំពីកិច្ចការរបស់អាជ្ញាធរទន្លេសាប ក៏ដូចជាកិច្ចការ របស់រាជរដ្ឋាភិបាល ជាពិសេសការចូលរួមលើកកម្ពស់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ ធនធានបឹងទន្លេសាប
- ការជំរុញកាលានុវត្តភាពពង្រឹងកិច្ចសហប្រតិបត្តិការយូរអង្វែងជាមួយដៃគូអភិវឌ្ឍន៍នានា ទាំង ក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ ក្នុងការកៀរគរជំនួយបច្ចេកទេស និងថវិកា ដើម្បីរៀបចំ កសាងឯកសារបច្ចេកទេស គោលនយោបាយ គម្រោង/កម្មវិធី ផែនការយុទ្ធសាស្ត្រ និងកសាង សមត្ថភាព ក្នុងការគាំទ្រដល់ដំណើរការងារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម តំបន់ជុំវិញបឹងទន្លេសាបប្រកបដោយចីរភាព
- ការផ្តល់ឱកាសក្នុងការផ្លាស់ប្តូរទស្សនៈនៃការយល់ដឹង ចែករំលែកបទពិសោធន៍ការងារ និង ការចាប់យកគំនិតថ្មីជាមួយបណ្តាប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍ ដែលពាក់ព័ន្ធនឹងចំណេះ ដឹងជំនាញក្នុងការគ្រប់គ្រងអាងទន្លេ ជាពិសេសអង្គការអាងទន្លេ និងគណៈកម្មការគ្រប់គ្រង អាងទន្លេក្នុងតំបន់ និងអន្តរជាតិ ដើម្បីចូលរួមការពារ និងគ្រប់គ្រងតំបន់ទន្លេសាប ។

## ៣.៤ សន្និដ្ឋាន និងទិសដៅការងារបន្ត

ផ្អែកលើសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ និងផែនការយុទ្ធសាស្ត្រ របស់ អាជ្ញាធរទន្លេសាប ២០២១-២០២៥ កន្លងមក **អាជ្ញាធរទន្លេសាប** បានធ្វើការវាយតម្លៃដោយយកចិត្ត ទុកដាក់បំផុតលើភាពខ្លាំង និងបញ្ហាប្រឈម ដែលតម្រូវឲ្យបន្តដោះស្រាយដោយភាពហ្មត់ចត់ នៅដំណាក់ កាលបន្ទាប់ក្នុងការរៀបចំ និងការអនុវត្តផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ សម្រាប់អាជ្ញាធរទន្លេសាប រយៈពេល ៥ ឆ្នាំ និងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដោយអនុលោមតាមស្មារតីនៃបេសកកម្មការងារក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់ទន្លេសាបប្រកបដោយចីរភាព ។ ជាពិសេសចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ** ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី ៧ ដើម្បី**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិឲ្យខ្ពស់ត្រដែត ជម្រុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាន **ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០** ។

ក្នុងស្មារតីនេះ **អាជ្ញាធរទន្លេសាប** រៀបចំកសាង និងដាក់ចេញនូវផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ និងផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ រយៈពេល ៥ ឆ្នាំ ដោយយោងលើកត្តាចាំបាច់ក្នុង បរិយាកាសសំខាន់ៗ ដូចខាងក្រោម ៖

– ការបន្តពង្រឹង និងពង្រីកសមិទ្ធផលការងារ ដែលអាជ្ញាធរទន្លេសាប សម្រេចបាននៅក្នុងដំណាក់កាលកន្លងមក នៅក្នុងក្របខ័ណ្ឌបេសកកម្មការងារដូចបានកំណត់ក្នុង ច្បាប់បទដ្ឋានគតិយុត្តិ និងដំណើរការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប
– ការបន្តកែលម្អ និងអភិបាលកិច្ចការងាររបស់អង្គភាព ឲ្យសម្រេចបាននូវប្រព័ន្ធគ្រប់គ្រងការងារប្រកបដោយប្រសិទ្ធភាពនៅក្នុងទិដ្ឋភាពសុខដុមនីយកម្មផ្ទៃក្នុងការងារ និងកិច្ចសហប្រតិបត្តិការបណ្ដាដៃគូខាងក្រៅ ទាំងការដឹកនាំ ការសម្របសម្រួល ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារប្រចាំថ្ងៃ គោលនយោបាយ និងយុទ្ធសាស្ត្រនានា
– ការបន្តកសាង និងពង្រឹងមូលដ្ឋានដ៏រឹងមាំរបស់អាជ្ញាធរទន្លេសាប ក្នុងការយកចិត្តទុកដាក់ជំរុញការលើកទឹកចិត្ត និងពង្រឹងការកសាងធនធានមនុស្សឲ្យបានគ្រប់ជ្រុងជ្រោយ តាមរយៈការគិតគូរដល់មន្ត្រីបន្តវេណ និងកសាងសមត្ថភាពចំណេះដឹង ជំនាញ លើកិច្ចការសិក្សាស្រាវជ្រាវ ការធ្វើវិភាគ ការធ្វើពិសោធន៍ ការរៀបចំចងក្រងសរសេររបាយការណ៍បច្ចេកទេស ការគ្រប់គ្រងព័ត៌មាន ទិន្នន័យ ការប្រាស្រ័យទាក់ទង ការតាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃដំណើរការការងារ និងការអនុវត្តកម្មវិធី/គម្រោង ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយរបស់អង្គភាព ដើម្បីបន្តការកែលម្អឲ្យបានកាន់តែប្រសើរឡើង ស្របតាមបរិការណ៍សង្គមឌីជីថល
– ការបន្តពង្រឹងអនុវត្តការចុះសិក្សាស្រាវជ្រាវ និងសិក្សាស្វែងយល់ពីព័ត៌មាន ទិន្នន័យ ដែលមានលក្ខណៈវិទ្យាសាស្ត្រ ស្របតាមបរិបទបច្ចេកវិទ្យាថ្មីសង្គមឌីជីថល ដើម្បីធ្វើជាមូលដ្ឋានដ៏រឹងមាំសម្រាប់ធ្វើការវិភាគ ក្នុងការរៀបចំកសាងឯកសារបច្ចេកទេស កម្មវិធី/គម្រោងសកម្មភាព គោលនយោបាយ ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធ ដែលជាអាទិភាពការងារស្នូលរបស់អាជ្ញាធរទន្លេសាប រួមមាន ៖ **របាយការណ៍ស្ថានភាពអាងបឹងទន្លេសាប, ការរៀបចំផែនទីតំបន់ទន្លេសាប, គោលនយោបាយ/ផែនការយុទ្ធសាស្ត្រ/ផែនការចង្អុល/ផែនការមេ សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាប, ការគ្រប់គ្រងធនធានទឹកចម្រុះអាងបឹងទន្លេសាប និងយុទ្ធសាស្ត្រគ្រប់គ្រងសហគមន៍តំបន់បឹងទន្លេសាប បន្សាំជាមួយបម្រែបម្រួលអាកាសធាតុ** សម្រាប់ ជម្រុញប្រសិទ្ធភាពដល់ការសម្របសម្រួល និងលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់សហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងម្ចាស់ជំនួយជាតិ និងអន្តរជាតិ ដើម្បីចូលរួមលើកកម្ពស់ដល់ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងអភិវឌ្ឍសេដ្ឋកិច្ចសង្គមតំបន់បឹងទន្លេសាបប្រកបដោយចីរភាព
– ការបន្តលើកកម្ពស់ប្រសិទ្ធភាពការងារប្រព័ន្ធគ្រប់គ្រងព័ត៌មាន ទិន្នន័យ បណ្ដាញផ្សព្វផ្សាយ និងចែករំលែក ព័ត៌មានចំណេះដឹងឲ្យបានកាន់តែខ្លាំងក្លា តាមរយៈនៃការពង្រឹងការយកចិត្តទុកដាក់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន ការប្រាស្រ័យទាក់ទង និងបច្ចេកវិទ្យា ដើម្បីលើកកម្ពស់

ប្រសិទ្ធភាពការងារស្នូលរបស់អង្គភាពឲ្យកាន់តែមានភាពរឹងមាំ ដើរស្របនឹងបច្ចេកវិទ្យាថ្មីៗក្នុងសង្គមឌីជីថល

- ការបន្តពង្រឹងភាពជាដៃគូ និងជំរុញកិច្ចសហប្រតិបត្តិការទាំងក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ ដើម្បីកៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការចូលរួមលើកកម្ពស់អភិបាលកិច្ច ដំណើរការការងារ និងចូលរួមគាំទ្រការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមតំបន់បឹងទន្លេសាបប្រកបដោយចីរភាព ។

ក្នុងស្មារតីបន្តរៀបចំ និងអនុវត្តនូវផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ និងផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ រយៈពេល ៥ ឆ្នាំ នេះ ។ អាជ្ញាធរទន្លេសាប បានសំលឹងឃើញនូវគោលបំណង និងកម្មវត្ថុច្បាស់លាស់ ក្នុងការជំរុញកិច្ចការស្នូលរបស់អង្គភាព ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ** ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី ៧ ដើម្បី**កំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិឲ្យខ្ពស់ត្រដែត ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាន **ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០** ។ កត្តានៃការសំម្លឹងឆ្ពោះទៅអនាគតរបស់អាជ្ញាធរទន្លេសាប រួមមាន ៖

- អាជ្ញាធរទន្លេសាប ជាអង្គភាពប្រមូលផ្តុំ ឬកន្លែងផ្ទុកដោយព័ត៌មានទិន្នន័យពាក់ព័ន្ធនឹងតំបន់បឹងទន្លេសាប (Tonle Sap Information/Data Bank) ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ និងអាចទុកចិត្តបាន សម្រាប់អ្នកស្រាវជ្រាវ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នករៀបចំគោលនយោបាយ យកទៅប្រើប្រាស់ និងវិភាគតាមតម្រូវការ
- អាជ្ញាធរទន្លេសាប ជាអង្គភាព ប្រមូលផ្តុំ ពូនជ្រុំនូវធនធានមនុស្ស ដែលប្រកបដោយចំណេះដឹង និងជំនាញច្បាស់លាស់ លើការសិក្សាស្រាវជ្រាវ និងវិភាគមានលក្ខណៈវិទ្យាសាស្ត្រ ដែលមានការវិវត្តទៅតាមបរិបទសង្គមឌីជីថល ដើម្បីជួយលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងអង្គភាព និងសង្គមជាតិ
- អាជ្ញាធរទន្លេសាប ជាអង្គភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយគុណតម្លៃ ដែលជាសេនាធិការផ្ទាល់ឲ្យរាជរដ្ឋាភិបាល ក្នុងការគិតគូរដោយហ្មត់ចត់លើការរក្សាបាននូវតុល្យភាពនៃការគ្រប់គ្រង និងអភិវឌ្ឍធនធានធម្មជាតិតំបន់បឹងទន្លេសាប ឲ្យប្រកបដោយនិរន្តរភាព ហើយក៏នឹងក្លាយជាដៃគូដ៏សំខាន់ជាមួយក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងកម្រិតជាតិ និងអន្តរជាតិ
- អាជ្ញាធរទន្លេសាប ជាអង្គភាព ប្រកបដោយឧត្តមភាពការងារក្នុងការសម្របសម្រួលដល់ការគ្រប់គ្រងធនធានទឹក បរិស្ថាន និងធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាប ស្របតាមគោលការណ៍ដែលបានកំណត់ក្នុងក្របខ័ណ្ឌអភិក្រមគ្រប់គ្រងអាងទន្លេ (River Basin Management Approach) និងក្លាយជាដៃគូយ៉ាងជិតស្និទជាមួយបណ្តាប្រទេសដែលជាសមាជិកអង្គការអាងទន្លេ (River Basin Organization)។

## IV. ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់អាជ្ញាធរទន្លេសាប

អនុលោមតាមផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប រយៈពេល ៥ ឆ្នាំ (២០២៤-២០២៨) ដែលបានដាក់ចេញគោលដៅយុទ្ធសាស្ត្រ រួមជាមួយទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដូចខាងក្រោម ៖

ក. គោលដៅទី ១. អភិវឌ្ឍព័ត៌មាន និងទិន្នន័យឲ្យកាន់តែប្រសើរឡើង អំពីតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

- ពង្រឹងការសិក្សាស្រាវជ្រាវលើទិដ្ឋភាពធនធានធម្មជាតិ បរិស្ថាន និងសេដ្ឋកិច្ចសង្គមតំបន់បឹងទន្លេសាប
- ពង្រឹងប្រសិទ្ធភាពយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃផលប៉ះពាល់ធនធានធម្មជាតិ បរិស្ថាន និងសេដ្ឋកិច្ចសង្គម
- លើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រងព័ត៌មាន ទិន្នន័យតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

ខ. គោលដៅទី ២. លើកកម្ពស់ការយល់ដឹង អប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាល

- ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព
- លើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រងបណ្តាញប្រព័ន្ធផ្សព្វផ្សាយ និងការចែករំលែកចំណេះដឹង

គ. គោលដៅទី ៣. ពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ

- ពង្រឹងប្រសិទ្ធភាពការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការជាតិ តំបន់ និងអន្តរជាតិ
- លើកកម្ពស់ប្រសិទ្ធភាពការចូលរួមរបស់ភាគីពាក់ព័ន្ធ

ឃ. គោលដៅទី ៤. លើកកម្ពស់សមត្ថភាពការងារ និងពង្រឹងការគ្រប់គ្រងស្ថាប័ន

- អភិវឌ្ឍសមត្ថភាពការងាររបស់អាជ្ញាធរទន្លេសាប ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល
- សម្របសម្រួល និងពង្រឹងសមត្ថភាពការងារជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ

ង. គោលដៅទី ៥. លើកកម្ពស់ និងអភិវឌ្ឍការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានឌីជីថល

- អភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធគាំទ្របរិវត្តកម្មឌីជីថល

លើកកម្ពស់ការកសាងសមត្ថភាពធនធានមនុស្ស និងនវានុវត្តន៍ឌីជីថល

ដ្យាក្រាម គំនូសបំព្រួញរចនាសម្ព័ន្ធចក្ខុវិស័យ បេសកកម្ម និងគោលដៅផែនការយុទ្ធសាស្ត្រ



# V. ផែនការសកម្មភាពការងារឆ្នាំ ២០២៤

## ៤.១. សេចក្តីផ្តើម

ផែនការសកម្មភាពការងារឆ្នាំ ២០២៤ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ជាសកម្មភាពការងារលម្អិត សម្រាប់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាបប្រតិបត្តិការងារជាក់ស្តែង ដោយមានការចូលរួមសហការពីបណ្តាក្រសួង-ស្ថាប័នទាំងក្នុងកម្រិត ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ សង្គមស៊ីវិល អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍនានា ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល ៥ ឆ្នាំ (២០២៤-២០២៨) ឲ្យទទួលបានជោគជ័យ ។

ជារួម ផែនការសកម្មភាពការងារ ត្រូវបានរៀបចំឡើងដោយបន្សីជាមួយគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ នៃផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ របស់អាជ្ញាធរទន្លេសាប ស្របតាមតួនាទីភារកិច្ចការងារទទួលខុសត្រូវ ដូចបានកំណត់ក្នុងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្មការងារស្នូលរបស់អាជ្ញាធរទន្លេសាបក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព ។

ផែនការសកម្មភាពការងារឆ្នាំ ២០២៤ មានសកម្មភាពចំនួន ២៨ សកម្មភាព ដែលសកម្មភាពទាំងនោះស្ថិតក្នុងសកម្មភាពយុទ្ធសាស្ត្រ ទិសដៅយុទ្ធសាស្ត្រ និងគោលដៅយុទ្ធសាស្ត្រ នៃផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល ៥ ឆ្នាំ (២០២៤-២០២៨) ។

# ៤.២ តារាងម៉ាទ្រិចផែនការសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ឆ្នាំ២០២៤

| គម្រោង/សកម្មភាព | ពេលវេលាអនុវត្តន៍ ២០២៤ ( ខែ ) | | | | | | | | | | | | អង្គភាពអនុវត្តន៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| SG1-គោលដៅយុទ្ធសាស្ត្រ ១. អភិវឌ្ឍព័ត៌មាន និងទិន្នន័យឲ្យកាន់តែប្រសើរឡើងអំពីតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | | | |
| SO1-ទិសដៅយុទ្ធសាស្ត្រ ១.១. ពង្រឹងការសិក្សាស្រាវជ្រាវលើទិដ្ឋភាពនៃធនធានធម្មជាតិ បរិស្ថាន និងសេដ្ឋកិច្ចសង្គមតំបន់ទន្លេសាប | | | | | | | | | | | | | |
| SA1-សកម្មភាពយុទ្ធសាស្ត្រ ១.១.១. សិក្សាពីការគ្រប់គ្រង និងអភិវឌ្ឍនាពេលអតីតកាល និងបច្ចុប្បន្នកាលក្នុងតំបន់បឹងទន្លេសាប | | | | | | | | | | | | | |
| A1 ១.១.១.១.សិក្សាស្វែងយល់សក្តានុពល និងការគ្រប់គ្រងតំបន់អភិរក្សក្នុងបណ្តាខេត្តទាំង៦ ជុំវិញបឹងទន្លេសាប | | | | | | | | | | | | | ន.ដ្ឋានត្រួតពិនិត្យការធ្វើ អាជីវកម្ម និងអភិរក្ស ការិយាល័យអភិរក្ស |
| សិក្សាស្វែងយល់សក្តានុពល និងវាយតម្លៃការគ្រប់គ្រងតំបន់អភិរក្សទាំង ៦ ក្នុងបឹងទន្លេសាប | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| របាយការណ៍សកម្មភាព | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| របាយការណ៍វឌ្ឍនភាពការងារប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ | | | √ | | | √ | | | √ | | | √ | |
| របាយការណ៍បច្ចេកទេស | | | | | | | | | | | √ | √ | |
| A2 ១.១.១.២.សិក្សាស្វែងយល់កាលានុវត្តភាពតំបន់បឹងទន្លេសាបក្នុងសេវាកម្មទេសចរណ៍ | | | | | | | | | | | | | អគ្គលេខាធិការដ្ឋាន |
| សិក្សាស្វែងយល់កាលានុវត្តភាពតំបន់បឹងទន្លេសាបក្នុងសេវាកម្មទេសចរណ៍នៅខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តសៀមរាប | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| របាយការណ៍សកម្មភាព | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស ឆមាស ប្រចាំឆ្នាំ | | | √ | | | √ | | | √ | | | √ | |
| របាយការណ៍បច្ចេកទេស | | | | | | | | | | | | √ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| A3 | ១.១.១.៣.សិក្សាស្រាវជ្រាវកាកសំណល់ឧបករណ៍នេសាទនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | | អគ្គលេខាធិការដ្ឋាន |
| សិក្សាស្រាវជ្រាវកាកសំណល់ឧបករណ៍នេសាទខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តសៀមរាប | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| របាយការណ៍សកម្មភាព | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស ឆមាស ប្រចាំឆ្នាំ | | | √ | | | √ | | | √ | | | √ | |
| របាយការណ៍បច្ចេកទេស | | | | | | | | | | | | √ | |
| A4 | ១.១.១.៤. សិក្សាស្រាវជ្រាវពីសក្តានុពលធនធានរ៉ែក្នុងបឹងទន្លេសាប និងតាមអាងស្ទឹងទាំង ១១ នៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | | ន.ដ្ឋានធនធានធម្មជាតិ ការិយាល័យធនធានរ៉ែ |
| បច្ចុប្បន្នភាពទីតាំងធនធានរ៉ែ នៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | | | | | | √ | | | √ | | | |
| តាមដាន និងវាយតំលៃពីសក្តានុពលធនធានរ៉ែ និងចំណាត់ថ្នាក់ | | | √ | | | | | √ | | | | | |
| វាយតម្លៃកំណកនៃធនធានរ៉ែខ្សាច់ និងវាយតម្លៃលើការប្រែប្រួលធនធានរ៉ែក្នុងអាងស្ទឹងទាំង ១១ (ខេត្តកំពង់ឆ្នាំង-ខេត្តពោធិ៍សាត់) | | √ | | √ | | | | | | | | | |
| វាយតម្លៃកំណកនៃធនធានរ៉ែខ្សាច់ និងវាយតម្លៃលើការប្រែប្រួលធនធានរ៉ែក្នុងអាងស្ទឹងទាំង ១១ (ខេត្តបាត់ដំបង-ខេត្តបន្ទាយមានជ័យ) | | | | | √ | | | | √ | | | | |
| វាយតម្លៃកំណកនៃធនធានរ៉ែខ្សាច់ និងវាយតម្លៃលើការប្រែប្រួលធនធានរ៉ែក្នុងអាងស្ទឹងទាំង ១១ (ខេត្តសៀមរាប-ខេត្តកំពង់ធំ) | | | | | | √ | | | | | √ | | |
| រៀបចំបង្ហាញផែនទីទីតាំងធនធានរ៉ែ ក្នុងបឹងទន្លេសាប និងអាងស្ទឹងទាំង ១១ និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | √ | √ | |
| របាយការណ៍សកម្មភាព | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស ឆមាស ប្រចាំឆ្នាំ | | | √ | | | √ | | | √ | | √ | √ | |
| A5 | ១.១.១.៥. សិក្សាស្រាវជ្រាវពីបម្រែបម្រួលគម្របដី និងការប្រើប្រាស់ដីនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | | ន.ដ្ឋានធនធានធម្មជាតិ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បច្ចុប្បន្នភាពទិន្នន័យដី ដី ថ្នាំកសិកម្មក្នុងខេត្តកំពង់ឆ្នាំង | | √ | | √ | | | | √ | | | | | ការិយាល័យកសិកម្មចម្រុះ |
| | បច្ចុប្បន្នភាពទិន្នន័យដី ដី ថ្នាំកសិកម្មក្នុងខេត្តបាត់ដំបង | | | | | √ | | √ | | √ | | √ | | |
| | បច្ចុប្បន្នភាពទិន្នន័យដី ដី ថ្នាំកសិកម្មក្នុងខេត្តបន្ទាយមានជ័យ | | | √ | | | √ | | | | √ | √ | | |
| | តាមដាន វាយតម្លៃ និងផ្ទៀងផ្ទាត់ព័ត៌មាន-ទិន្នន័យប្រមូលបាន និងសំណាកវិភាគដីចំនួន ១២ ប៉ារ៉ាម៉ែត្រ (លក្ខណៈរូប-គីមី) | | | | | | | | | | | √ | | |
| | លទ្ធផលវិភាគពីបម្រែបម្រួលគម្របដី និងការប្រើប្រាស់ដី | | | | | | | | | | | √ | √ | |
| | រៀបចំផែនទីគម្របដី និងការប្រើប្រាស់ដី | | | | | | | | | | | √ | √ | |
| | របាយការណ៍សកម្មភាព | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| | របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស ឆមាស ប្រចាំឆ្នាំ | | | √ | | | √ | | | √ | | √ | √ | |
| A6 | ១.១.១.៦. សិក្សាស្រាវជ្រាវពីបម្រែបម្រួលធនធានជលផលនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | | | ន.ដ្ឋានធនធានធម្មជាតិ<br>ការិយាល័យជីវចម្រុះ |
| | បច្ចុប្បន្នភាពប្រភេទ និងលក្ខណៈជីវសាស្ត្រធនធានជលផលទៅតាមទីជម្រក ចំណី និងបរិស្ថានទឹក (វាយតម្លៃបឋមគុណភាពទឹកតាមទីតាំងចុះសិក្សា) និងតំបន់ពាក់ព័ន្ធ (ខេត្តកំពង់ឆ្នាំង, ខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ) | √ | √ | √ | | √ | √ | √ | √ | √ | | √ | | |
| | បច្ចុប្បន្នភាពប្រភេទ និងលក្ខណៈជីវសាស្ត្រធនធាន ជលផលទៅតាមទីជម្រក ចំណី និងបរិស្ថានទឹក (វាយតម្លៃបឋមគុណភាពទឹកតាមទីតាំងចុះសិក្សា) និងតំបន់ពាក់ព័ន្ធ (ខេត្តបាត់ដំបង និងខេត្តសៀមរាប) | | √ | | √ | | | | √ | | √ | | | |
| | វាយតម្លៃលើការបន្លាស់ទីធនធានជលផលតាមស្ទឹង និងលក្ខណៈជីវសាស្ត្ររបស់ត្រី និងក្រៅពីត្រី | | | √ | √ | | √ | | | | √ | | | |
| | វាយតម្លៃប្រភេទធនធានជលផលនៅតាមដងទន្លេសាប (កណ្តាល-ភ្នំពេញ-កំពង់ឆ្នាំង) នៅតាមឡូត៍ដាយត្រីនិងតំបន់ពាក់ព័ន្ធ | √ | | | | | | | | | | √ | √ | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចងក្រងសៀវភៅ និងរៀបចំរបាយការណ៍ស្តីពី ប្រភេទធនធានជលផលនៅតំបន់អាងទន្លេសាប | | | | | | | | | | | √ | √ | |
| | របាយការណ៍សកម្មភាព | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |
| | របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស ឆមាស ប្រចាំឆ្នាំ | | | √ | | | √ | | | √ | | √ | √ | |
| A7 | ១.១.១.៧. សិក្សាស្រាវជ្រាវពីសក្តានុពលធនធានទឹកនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | | | |
| | បន្តការតាមដាន និងបច្ចុប្បន្នភាពរបបជលសាស្ត្រ-ឧតុនិយមនៅក្នុងអាងទន្លេសាប (១១ស្ទឹង និងបឹងទន្លេសាប) | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| | បន្តការវាយតម្លៃបរិមាណលំហូរទឹក/ធារទឹកស្ទឹងនៅតាមបណ្តាអាងស្ទឹងជុំវិញតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ (ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តកំពង់ធំ) | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | ន.ដ្ឋានធនធានធម្មជាតិ<br>ការិយាល័យធនធានទឹក |
| | បន្តបច្ចុប្បន្នភាពប្រព័ន្ធធារាសាស្ត្រនៅក្នុងអាងស្ទឹង និងស្វែងរកប្រភពធនធានទឹក លទ្ធភាពប្រើប្រាស់ ព្រមទាំងវាយតម្លៃលើការគ្រប់គ្រងធនធានទឹកនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| | របាយការណ៍សកម្មភាព | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |
| | របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស ឆមាស ប្រចាំឆ្នាំ | | | √ | | | √ | | | √ | | √ | √ | |
| A8 | ១.១.១.៨.សិក្សាស្រាវជ្រាវពីគុណភាពទឹកនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | | | |
| | វាយតម្លៃផលប៉ះពាល់បរិស្ថាន នៅតំបន់ផ្លូកទ្រូ, តំបន់ផាត់សណ្តាយ (ដី-ភូមិបណ្តែតទឹក) និងសំណាកទឹក | | √ | | √ | √ | | √ | | | √ | | | |
| | វាយតម្លៃផលប៉ះពាល់បរិស្ថាន នៅតំបន់ចុងឃ្នៀស (ដី-ភូមិបណ្តែតទឹក) និងសំណាកទឹក | | | √ | | | √ | | √ | √ | | | | ន.ដ្ឋានធនធានធម្មជាតិ |
| | វាយតម្លៃប្រភេទ និងប្រភពកាកសំណល់ក្នុងតំបន់សិក្សា និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | √ | | |
| | វាយតម្លៃបឋមលើសំណាកទឹកចំនួន ១៣ ប៉ារ៉ាម៉ែត្រ (លក្ខណៈរូប-គីមី) ក្នុងតំបន់សិក្សា | | | | | | | | | | | √ | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| របាយការណ៍សកម្មភាព | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស ឆមាស ប្រចាំឆ្នាំ | | | | √ | | | √ | | | √ | | √ | √ | |
| A9 | ១.១.១.៩.សិក្សាវាយតម្លៃផលចាប់ នៃធនធានត្រីខេត្តកំពង់ឆ្នាំង | | | | | | | | | | | | | ទីប្រឹក្សា អទស<br>ន.ដ្ឋានរដ្ឋបាល ផែនការ<br>និងសហប្រតិប្តិការ |
| សិក្សាវាយតម្លៃផលចាប់នៃធានធនត្រីនៅតំបន់ស្រុកបរិបូរណ៍ ឃុំឆ្នុកទ្រូ ឃុំកំពង់ព្រះគគីរ និងឃុំត្រពាំងចាន់ ស្រុកកំពង់លែង ឃុំផ្លូវទូក ឃុំប្រឡាយមាស និងឃុំកំពង់ហាវ ក្រុងកំពង់ឆ្នាំង សង្កាត់ផ្សារឆ្នាំង និងសង្កាត់ខ្សាម | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |
| សិក្សាវាយតម្លៃផលចាប់នៃធនធានត្រីនៅតំបន់ ស្រុកកំពង់ត្រឡាច ឃុំសែប ឃុំអំពិលទឹក ឃុំតាជេស ឃុំលង្វែក និងឃុំកំពង់ត្រឡាច ស្រុករលាប្អៀរ ឃុំទឹកហូត ឃុំគោកបន្ទាយ និងឃុំស្វាយជ្រុំ ស្រុកជលគីរី ឃុំកោះថ្កូវ ឃុំជលសារ ឃុំកំពង់អុស ឃុំព្រៃគ្រី និងឃុំពាមឆ្កោក | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |
| របាយការណ៍សកម្មភាព | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |
| របាយការណ៍តាមដានការអនុវត្តសកម្មភាពត្រីមាស ឆមាស ប្រចាំឆ្នាំ | | | | √ | | | √ | | | √ | | | √ | |
| របាយការណ៍បច្ចេកទេស | | | | | | | | | | | | | √ | |
| SA2-សកម្មភាពយុទ្ធសាស្ត្រ ១.១.២. សិក្សាពីច្បាប់បទប្បញ្ញត្តិ គោលនយោបាយ និងការអនុវត្តដែលមានស្រាប់ សម្រាប់និរន្តរភាពធនធានធម្មជាតិ បរិស្ថានតំបន់បឹងទន្លេសាប | | | | | | | | | | | | | | |
| SA3-សកម្មភាពយុទ្ធសាស្ត្រ ១.១.៣. សិក្សាស្រាវជ្រាវពីស្ថានភាពបរិស្ថានតំបន់បឹងទន្លេសាប រួមបញ្ចូលទាំងបម្រែបម្រួលគម្របដី ព្រៃលិចទឹក ជីវចម្រុះ ធនធានទឹក បម្រែបម្រួលអាកាសធាតុ និងទិដ្ឋភាពសេដ្ឋកិច្ចសង្គមក្នុងតំបន់ទន្លេសាប | | | | | | | | | | | | | | |
| A10 | ១.១.៣.១.សិក្សា តាមដាន និងវាយតម្លៃធនធានជលផលលើការធ្វើអាជីវកម្មធនធានធម្មជាតិនៅខេត្តទាំង៦ ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ | | | | | | | | | | | | | ន.ដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើ |
| តាមដាន វាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ សិប្បីសត្វ និងចរន្តទីផ្សារតាមច្រកចេញ-ចូលនៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សិក្សា តាមដាន និងវាយតម្លៃការធ្វើអាជីវកម្មនេសាទនៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | ធនធានធម្មជាតិ |
| | របាយការណ៍បេសកកម្ម | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | |
| | របាយការណ៍វឌ្ឍនភាពការងារប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ | | | √ | | | √ | | | √ | | | √ | |
| | របាយការណ៍បច្ចេកទេស | | | | | | | | | | | √ | √ | |
| A11 | ១.១.៣.២.សិក្សាតាមដានអាជីវកម្មឡូត៍ដាយរដូវនេសាទឆ្នាំ ២០២៤-២០២៥ | | | | | | | | | | | | | អគ្គលេខាធិការដ្ឋាន ន.ដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ន.ដ្ឋានធនធានធម្មជាតិ ន.ដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ & ន.ដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ |
| | សិក្សាតាមដានបរិមាណផលឡូត៍ដាយត្រីលេខ ២ A | √ | √ | | | | | | | | √ | √ | √ | |
| | សិក្សាតាមដានបរិមាណផលឡូត៍ដាយត្រីលេខ ៧ G | √ | √ | | | | | | | | √ | √ | √ | |
| | សិក្សាតាមដានបរិមាណផលឡូត៍ដាយត្រីលេខ ១១ A | √ | √ | | | | | | | | √ | √ | √ | |
| | សិក្សាតាមដានបរិមាណផលឡូត៍ដាយត្រីលេខ ១៣ A | √ | √ | | | | | | | | √ | √ | √ | |
| | សិក្សាតាមដានបរិមាណផលឡូត៍ដាយត្រីលេខ ១៤ A | √ | √ | | | | | | | | √ | √ | √ | |
| | សិក្សាតាមដានបរិមាណផលឡូត៍ដាយត្រីលេខ ១៥ E | √ | √ | | | | | | | | √ | √ | √ | |
| | របាយការណ៍សកម្មភាព | √ | √ | | | | | | | | √ | √ | √ | |
| | របាយការណ៍វឌ្ឍនភាពការងារប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ | | | √ | | | √ | | | √ | | | √ | |
| | របាយការណ៍បច្ចេកទេស | | | | | | | | | | | √ | √ | |
| A12 | ១.១.៣.៣.សិក្សាស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ (Livelihood) លើការប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថាននៅជុំវិញតំបន់បឹងទន្លេសាប | | | | | | | | | | | | | អគ្គលេខាធិការដ្ឋាន ន.ដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ & ន.ដ្ឋានរដ្ឋបាល ផែនការ និង |
| | ប្រមូលឯកសារពាក់ព័ន្ធ និងលើកសំណើអនុវត្តន៍ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ធ្វើបច្ចុប្បន្នភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមរបស់ប្រជាសហគមន៍នេសាទ ខេត្តកំពង់ឆ្នាំង | | √ | | | | | | √ | | | | | សហប្រតិបត្តិការ |
| ធ្វើបច្ចុប្បន្នភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមរបស់ប្រជាសហគមន៍នេសាទ ខេត្តពោធិ៍សាត់ | | | √ | | | | | | √ | | | | |
| ធ្វើបច្ចុប្បន្នភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមរបស់ប្រជាសហគមន៍នេសាទ ខេត្តបាត់ដំបង | | | | √ | | | | | | √ | | | |
| ធ្វើបច្ចុប្បន្នភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមរបស់ប្រជាសហគមន៍នេសាទ ខេត្តបន្ទាយមានជ័យ | | | | | √ | | | | | | | | |
| ធ្វើបច្ចុប្បន្នភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមរបស់ប្រជាសហគមន៍នេសាទ ខេត្តសៀមរាប | | | | | | √ | | | | | √ | | |
| SA20-សកម្មភាពយុទ្ធសាស្ត្រ ២.២.៣. រៀបចំ និងផលិតរបាយការណ៍ ស្តីពីស្ថានភាពបឹងទន្លេសាប ( The Report on State of the Tonle Sap Lake ) | | | |
| SA21-សកម្មភាពយុទ្ធសាស្ត្រ ២.២.៤. រៀបចំ និងផលិតផែនទី ឬរូបភាពលើអាកាសតំបន់ទន្លេសាប ( Mapping/Aerial Photo for the Tonle Sap Region ) | | | |
| SO6-ទិសដៅយុទ្ធសាស្ត្រ ២.៣. លើកកម្ពស់សមត្ថភាពយេនឌ័រក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព | | | |
| SA22-សកម្មភាពយុទ្ធសាស្ត្រ ២.៣.១. បញ្ជ្រាបការយល់ដឹង និងកសាងសមត្ថភាពយេនឌ័រក្នុងការគ្រប់គ្រងធនធានធម្មជាតិតំបន់បឹងទន្លេសាប | | | |

| A22 | ២.២.១.២.លើកកម្ពស់ការយល់ដឹង និងកសាងសមត្ថភាពយេនឌ័រលើការគ្រប់គ្រងធនធានធម្មជាតិនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | | |
|---|---|---|---|
| លទ្ធផលរំពឹងទុក | | សូចនាករ | ន.ដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ |
| - ស្ត្រីនឹងទទួលបានការយល់ដឹង និងសកម្មភាពការចូលរួមរបស់យេនឌ័រក្នុងការការពារធនធានធម្មជាតិ<br>- ការចូលរួមរបស់ស្ត្រីនៅថ្នាក់សហគមន៍-ភូមិ និងថ្នាក់ឃុំ និងតំបន់អភិរក្សជលផល ព្រៃលិចទឹក ភូមិបណ្តែតទឹក និងទិដ្ឋភាពទូទៅនៃបឹងទន្លេសាបច្រើនជាងមុន | | - ចំនួន ២០ គោលដៅ២០វគ្គសម្រាប់លើកកម្ពស់នៅខេត្តជុំវិញបឹងទន្លេសាប<br>- ចំនួនស្ត្រី ២០ នាក់នឹងទទួលបានការលើកកម្ពស់យល់ដឹងក្នុង១វគ្គ | |

| |
|---|
| SA23-សកម្មភាពយុទ្ធសាស្ត្រ ២.៣.២. សម្របសម្រួល បញ្ជ្រាបសកម្មភាពយេនឌ័រទៅក្នុងផែនការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានសហគមន៍ |
| SG3-គោលដៅយុទ្ធសាស្ត្រ ៣. ពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធរបស់អាជ្ញាធរទន្លេសាប |
| SO7-ទិសដៅយុទ្ធសាស្ត្រ ៣.១. ពង្រឹងប្រសិទ្ធភាពការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការជាតិ តំបន់ និងអន្តរជាតិ |
| SA24-សកម្មភាពយុទ្ធសាស្ត្រ ៣.១.១. ពង្រឹងពង្រីកទំនាក់ទំនងក្នុងការកៀរគរហិរញ្ញវត្ថុពីប្រភពខាងក្រៅ |
| SA25-សកម្មភាពយុទ្ធសាស្ត្រ ៣.១.២. លើកកម្ពស់ និងពង្រីកបណ្តាញការងារក្រុមប្រឹក្សាយោបល់ម្ចាស់ជំនួយ របស់ដៃគូបច្ចេកទេស និងហិរញ្ញវត្ថុ |
| SA26-សកម្មភាពយុទ្ធសាស្ត្រ ៣.១.៣. កសាងរៀបចំបណ្តាញការងារ និងភាពជាដៃគូ សម្រាប់គាំទ្រដល់ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថានបឹងទន្លេសាប (ក្រុមប្រើប្រាស់ សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល សហគមន៍ កសិករ ឯកជន...) |
| SO8-ទិសដៅយុទ្ធសាស្ត្រ ៣.២. លើកកម្ពស់ប្រសិទ្ធភាពការចូលរួមរបស់ភាគីពាក់ព័ន្ធ |
| SA27-សកម្មភាពយុទ្ធសាស្ត្រ ៣.២.១. ជំរុញការអនុវត្តផែនការលើកទឹកចិត្តដល់ការចូលរួមរបស់ភាគីពាក់ព័ន្ធ |
| SA28-សកម្មភាពយុទ្ធសាស្ត្រ ៣.២.២. លើកកម្ពស់កិច្ចសហប្រតិបត្តិការពហុវិស័យ និងសម្របសម្រួលពង្រឹងកិច្ចសហប្រតិបត្តិការអន្តរភ្នាក់ងារ |
| SA29-សកម្មភាពយុទ្ធសាស្ត្រ ៣.២.៣. លើកកម្ពស់ការពិគ្រោះយោបល់អន្តរវិស័យ និងបង្កើនការយល់ដឹង |
| SA30-សកម្មភាពយុទ្ធសាស្ត្រ ៣.២.៤. លើកកម្ពស់ប្រសិទ្ធភាពកិច្ចសន្ទនា និងសម្របសម្រួលជាមួយបណ្តាភាគីដៃគូ ពាក់ព័ន្ធទាំងកម្រិតជាតិ តំបន់ និងអន្តរជាតិ |
| SA31-សកម្មភាពយុទ្ធសាស្ត្រ ៣.២.៥. សម្របសម្រួលពង្រឹងកិច្ចសហប្រតិបត្តិការអន្តរសមាគមន៍/អង្គការសង្គមស៊ីវិល នៅកម្រិតមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប |
| SA32-សកម្មភាពយុទ្ធសាស្ត្រ ៣.២.៦. សម្របសម្រួល និងលើកកម្ពស់ដល់ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមសហគមន៍តាមមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប |
| SG4-គោលដៅយុទ្ធសាស្ត្រ ៤. លើកកម្ពស់សមត្ថភាព និងពង្រឹងការគ្រប់គ្រងស្ថាប័នរបស់អាជ្ញាធរទន្លេសាប និងក្រសួង/ស្ថាប័នពាក់ព័ន្ធ |
| SO9-ទិសដៅយុទ្ធសាស្ត្រ ៤.១. អភិវឌ្ឍសមត្ថភាពការងាររបស់អាជ្ញាធរទន្លេសាបប្រកបដោយប្រសិទ្ធភាព និងសមិទ្ធផល |
| SA33-៤.១.១.ពង្រឹងសមត្ថភាពមន្ត្រីអាជ្ញាធរទន្លេសាប ក្នុងការគ្រប់គ្រងចំណេះដឹង និងប្រាស្រ័យទាក់ទង (យល់ដឹង/សម្លឹងមើលឃើញភាពរឹងមាំរបស់អាជ្ញាធរទន្លេសាប និងយុទ្ធសាស្ត្រ ប្រតិបត្តិការគ្រប់គ្រងចំណេះដឹង) |
| SA34-៤.១.២.លើកកម្ពស់ឧត្តមភាពការងាររបស់អាជ្ញាធរទន្លេសាបឲ្យមាននិរន្តរភាព |

| A23 | ៤.១.២.១.ពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងកិច្ចការងាររដ្ឋបាល បុគ្គលិក គណនេយ្យ ផែនការ និងសហប្រតិបត្តិការរបស់អាជ្ញាធរទន្លេសាប | |
|---|---|---|
| លទ្ធផលរំពឹងទុក | សូចនាករ | |
| - ការស្នើសុំដំឡើងតួនាទី ដំឡើងឋានន្តរស័ក្តិ ដំឡើងកាំប្រាក់ និងស្នើសុំផ្តល់គ្រឿងឥស្សរិយយស មន្ត្រីសកម្មអាជ្ញាធរទន្លេសាប និងចំនួនមន្ត្រី និងមន្ត្រីមានការកើនសម្រាប់គាំទ្រដំណើរការងារដល់អាជ្ញាធរទន្លេសាប<br>- សេវាកម្ម និងការផ្តត់ផ្គង់ផ្នែករដ្ឋបាលល្អប្រសើរសម្រាប់ដំណើរការងារដល់អាជ្ញាធរទន្លេសាប<br>- ថវិកាជាតិសម្រាប់ គាំទ្រដំណើរការងារអាជ្ញាធរទន្លេសាបមានការកើនឡើង និងរក្សាលំនឹង<br>- គម្រោងវិនិយោគសារធារណៈនឹងមានរៀបចំ និងដាក់បញ្ចូលទៅក្រសួងផែនការ<br>- ការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ និងម្ចាស់ជំនួយនឹងមានការសហការផែនការសកម្មភាព ២០២៥ | - ចំនួនមន្ត្រី សកម្មទទួលបានការលើកទឹកចិត្តដំឡើងតួនាទី ដំឡើងឋានន្តរស័ក្តិ តំឡើងកាំប្រាក់ និងស្នើសុំផ្តល់គ្រឿងឥស្សរិយយស<br>- ដំណើរការងារគ្រប់គ្រងបុគ្គលិក រដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានលក្ខណៈល្អប្រសើរ<br>- ចំនួនគម្រោងវិនិយោគ ៧ ត្រូវបានអនុម័តដាក់បញ្ចូលក្នុងកម្មវិធីរបស់ក្រសួងផែនការ<br>- ចំនួន ៥  គម្រោងសកម្មភាពការងារ( ក្រៅផែនការ ២០២៤ )មានការគាំទ្រពីម្ចាស់ជំនួយ<br>- ចំនួន ១០ ក្បាល ផែនការថវិកា ២០២៥-២០២៧<br>- ចំនួន ១០០ ក្បាល ផែនការសកម្មភាព ២០២៥ | ន.ដ្ឋាន រដ្ឋបាល ផែនការ និងសហប្រតិបត្តិការ |

| | | |
|---|---|---|
| A24 | ៤.១.១.២.ត្រួតពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់អាជ្ញាធរទន្លេសាប | |
| លទ្ធផលរំពឹងទុក | សូចនាករ | |
| - សេចក្តីរាយការណ៍ត្រួតពិនិត្យតាមដានជាទៀងរាល់ពេល និងរបាយការណ៍ត្រួតពិនិត្យតាមដានទៀងរាល់៣ខែក្នុង១ដង នៃការអនុវត្តសកម្មភាពសម្រាប់គាំទ្រដល់ ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់អាជ្ញាធរទន្លេសាប<br>- របាយការណ៍វឌ្ឍភាពការងារ ៦ ខែ និង ប្រចាំឆ្នាំ ២០២៤ របស់ អគ្គលេខាធិការដ្ឋាន<br>- វិធានការថ្មីៗក្នុងការអនុវត្តសកម្មភាពនៅពេលជួបហានិភ័យ | - ចំនួនសកម្មភាព ២៨ ទទួលបានការត្រួតពិនិត្យតាមដានជាទៀងរាល់ពេល និងវាយតម្លៃ<br>- របាយការណ៍តាមដាន និងវឌ្ឍនភាពត្រូវបានរៀបចំទៀងរាល់៣ខែក្នុង១ដង | នដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ការិយាល័យ ផែនការ និង សហប្រតិបត្តិការ |
| SA35-៤.១.៣.ពង្រឹងសមត្ថភាពស្ថាប័នក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | | |
| SA36-៤.១.៤. ពង្រឹងសមត្ថភាពមន្ត្រីបង្គោលតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប | | |
| SA37-៤.១.៥. ពង្រឹងតួនាទីសំខាន់របស់អាជ្ញាធរទន្លេសាប ជាមួយបណ្តាញការងាររបស់អង្គការអាងទន្លេ (River Basin Organization-RBO) | | |
| S10-ទិសដៅយុទ្ធសាស្ត្រ ៤.២. សម្របសម្រួល និងពង្រឹងសមត្ថភាពការងារជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ | | |
| SA38-៤.២.១. ពង្រឹងក្របខ័ណ្ឌច្បាប់ និងកិច្ចប្រតិបត្តិអនុវត្តការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាប ប្រកបដោយចីរភាព | | |
| SA39-៤.២.២. លើកកម្ពស់ការកសាងសមត្ថភាពធនធានមនុស្ស | | |
| SA40-៤.២.៣. រៀបចំកសាង និងអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ សហគមន៍មូលដ្ឋានក្នុងតំបន់បឹងទន្លេសាប | | |
| SA41-៤.២.៤. កសាងផែនការគ្រប់គ្រងអាងបឹងទន្លេសាប ឬការគ្រប់គ្រងធនធានទឹកចម្រុះប្រកបដោយចីរភាពក្នុងបឹងទន្លេសាប | | |
| SA42-៤.២.៥. កសាងផែនការយុទ្ធសាស្ត្រ សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍបឹងទន្លេសាប | | |
| SA43-៤.២.៦. កសាងផែនការមេ/ផែនទីបង្ហាញផ្លូវសម្រាប់តំបន់ទន្លេសាប | | |
| SG5-គោលដៅយុទ្ធសាស្ត្រ ៥. លើកកម្ពស់ និងអភិវឌ្ឍការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានឌីជីថល | | |
| S011-ទិសដៅយុទ្ធសាស្ត្រ ៥.១. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្របរិវត្តកម្មឌីជីថល | | |
| SA44-សកម្មភាពយុទ្ធសាស្ត្រ ៥.១.១. ពង្រឹងគុណភាព និងពង្រីកវិសាលភាពការគ្រប់គ្រងព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យា(Information, Communication, and Technology) | | |

| | | | |
|---|---|---|---|
| A25 | ៥.១.១.១.តម្លើងមជ្ឈមណ្ឌលទិន្នន័យរបស់អាជ្ញាធរទន្លេសាប Tonle Sap Authority Data Center | | អគ្គលេខាធិការដ្ឋាន |
| លទ្ធផលរំពឹងទុក | | សូចនាករ | |
| - ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច(Server) អ.ទ.ស ទៅលើការរក្សាទុក និងចែករំលែកព័ត៌មាន ទិន្នន័យរបស់អាជ្ញាធរទន្លេសាបក្នុងប្រព័ន្ធ Server នឹងប្រើប្រាស់ជាផ្លូវការបានល្អប្រសើរ ពីសំណាកមន្ត្រីអាជ្ញាធរទន្លេសាប<br>- មជ្ឈមណ្ឌលទិន្នន័យរបស់អាជ្ញាធរទន្លេសាបមានការថែទាំជាប្រចាំ | | - គ្រឿងបង្គុំគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងការតម្លើងមជ្ឈមណ្ឌលដំណើរការក្នុងប្រព័ន្ធ<br>- គ្រប់ព័ត៌មាន ទិន្នន័យរបស់អាជ្ញាធរទន្លេសាបដាក់បញ្ចូលតាមផ្នែកទៅក្នុងប្រព័ន្ធអេត្រូនិច<br>- ការថែទាំមជ្ឈមណ្ឌលជាប្រចាំ | |
| A26 | ៥.១.១.២.បច្ចុប្បន្នភាព និងពង្រឹងការគ្រប់គ្រងព័ត៌មាន ទិន្នន័យអាជ្ញាធរទន្លេសាប | | ន.ដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ការិយាល័យនីតិកម្ម |
| លទ្ធផលរំពឹងទុក | | សូចនាករ | |
| - ប្រព័ន្ធអេឡិចត្រូនិច (Server) របស់អាជ្ញាធរទន្លេសាបដំណើរការល្អ និងមានសុវត្ថិភាពក្នុងការរក្សាទុក និងចែករំលែកព័ត៌មាន ទិន្នន័យរបស់អាជ្ញាធរទន្លេសាបដល់អ្នកពាក់ព័ន្ធ<br>- ប្រព័ន្ធ Network និង Computer ដែលភ្ជាប់ទៅកាន់ Server និងមានដំណើរការល្អ ព្រមទាំងមាន Anti-Virus License នៅក្នុងម៉ាស៊ីននីមួយៗ | | - ចំនួនឯកសារព័ត៌មាន ទិន្នន័យដែលបានយកមករក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិច(Server) (របាយការណ៍ និងឯកសារពាក់ព័ន្ធ)<br>- មាន Software Anti-Virus សម្រាប់ការពារសុវត្ថិភាពម៉ាស៊ីនកំព្យូទ័រមន្ត្រី អ.ទ.ស យ៉ាងតិច ៨0 License<br>- ពិនិត្យតាមដានជួសជុលថែទាំប្រព័ន្ធអេឡិចត្រូនិច (Server) អ.ទ.ស ជាប្រចាំ<br>- ចំនួនឯកសាររៀបរយ តាមលំដាប់ (Code) ច្បាស់លាស់ងាយស្រួលស្វែងរក<br>- រាល់ឯកសារទាំងអស់ នឹងត្រូវបានរក្សាទុក គ្រប់គ្រងដោយសុវត្ថិភាព | |

| | | |
|---|---|---|
| SA45-សកម្មភាពយុទ្ធសាស្ត្រ ៥.១.២. រៀបចំបង្កើតបណ្ណាល័យអេឡិចត្រូនិច E-Library គ្រប់គ្រងការផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន ទិន្នន័យ និងចំណេះដឹងបឹងទន្លេសាប | | |
| A27 ៥.១.២.១.បង្កើតបណ្ណាល័យអេឡិចត្រូនិច (E-Library) | | ន.ដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ការិយាល័យផ្សព្វផ្សាយ |
| លទ្ធផលរំពឹងទុក | សូចនាករ | |
| - បណ្ណាល័យ E-Library មួយនឹងការបង្កើតប្រព័ន្ធបណ្ណាល័យឌីជីថលសម្រាប់ទុកដាក់ឯកសារ និងគ្រប់គ្រងឯកសារជាលក្ខណៈ Digitalប្រកបដោយសុវត្ថិភាព និងមានរបៀបរៀបរយ<br>- អ្នកទស្សនា អ្នកអាន នឹងទទួលបានសម្រាប់សេវាអ៊ីនធឺណេត<br>- អ្នកប្រើប្រាស់បណ្ណាល័យប្រចាំថ្ងៃនឹងកើនឡើងជាប្រចាំ | - អង្គចងចាំសម្រាប់ផ្ទុកឯកសារ របស់ E-Library មាន កម្រិត ១០០០ TB<br>- Application PC និងទូរស័ព្ទទទួលបានការប្រើប្រាស់ Library បានយ៉ាងល្អប្រសើរ<br>- មន្ត្រី អ.ទ.ស គ្រប់គ្នា និងអ្នកប្រើប្រាស់ E- Library ទទួលការយល់ពីការប្រាស់ច្បាស់លាស់ | |
| SA46-សកម្មភាពយុទ្ធសាស្ត្រ ៥.១.៣. រៀបចំកសាង និងអនុវត្តផែនការប្រាស្រ័យទាក់ទង (Communication Plan) ផ្តោតសំខាន់លើ ព័ត៌មានបច្ចេកទេស និងឧបករណ៍ឌីជីថល  កម្ពស់ការ | | |
| SO12-ទិសដៅយុទ្ធសាស្ត្រ ៥.២. លើកកម្ពស់ការកសាងសមត្ថភាពធនធានមនុស្ស និងនវានុវត្តឌីជីថល | | |
| SA47-៥.២.១.កសាងសមត្ថភាពធនធានមនុស្សឌីជីថល | | |
| A28 ៥.២.១.១.ពង្រឹង និងពង្រីកការកសាងសមត្ថភាពជូនមន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាប | | ន.ដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ការិយាល័យបុគ្គលិក និង បណ្តុះបណ្តាល |
| លទ្ធផលរំពឹងទុក | សូចនាករ | |
| - មន្ត្រីអាជ្ញាធរទន្លេសាបទទួលបានចំណេះដឹង វគ្គបណ្តុះបណ្តាលដែលបានគ្រោងទុក<br>- ចំណេះដឹង និងសមត្ថភាពមន្ត្រីអាជ្ញាធរទន្លេសាបមានការកើនឡើងតាមជំនាញ<br>- របាយការណ៍ការវាយតម្លៃលើសមត្ថភាព និងចំណេះដឹងមន្ត្រីមុន និងក្រោយពេលបណ្តុះបណ្តាល | - ចំនួន ៥ វគ្គបណ្តុះបណ្តាល នៅរាជធានីភ្នំពេញ និងខេត្តជុំវិញបឹងទន្លេសាប<br>- ចំនួន ៣៥ នាក់ក្នុង១វគ្គ ៣ ទៅ ៤ ថ្ងៃ | |
| SA48-៥.២.២. លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល | | |

## ៤.៤ ធនធានហិរញ្ញវត្ថុអនុវត្តសកម្មភាពប្រចាំឆ្នាំ ២០២៤

ផែនការសកម្មភាពការងារ របស់អាជ្ញាធរទន្លេសាបនឹងត្រូវអនុវត្តបានតាមរយៈការលើកសំណើរបស់នាយកដ្ឋានទាំង ០៤ និងអ្នកអនុវត្តន៍សកម្មភាព ក្រោយពីផែនការសកម្មភាពការងារឆ្នាំ ២០២៤ អនុម័តរួច និងដាក់ឲ្យអនុវត្តជាផ្លូវការស្របតាមផែនការថវិកាកម្មវិធីរបស់រាជរដ្ឋាភិបាល។

អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ជាអ្នករៀបចំ អនុវត្ត គ្រប់គ្រង និងដឹកនាំលើការអនុវត្តសកម្មភាពការងារនេះដែលមាននាយកដ្ឋានជំនាញទាំង៤ជាអ្នកទទួលខុសត្រូវលើការអនុវត្តសកម្មភាពរៀងៗខ្លួនតាមជំនាញ ។ នាយកដ្ឋាន ទាំង៤ និងអ្នកអនុវត្តន៍ ត្រូវលើកសំណើដើម្បីអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំដោយផ្អែកលើសកម្មភាពដែលបានកំណត់ក្នុងផែនការសកម្មភាពការងារនេះ និងដោយអនុលោមតាមតួនាទី ភារកិច្ចរបស់នាយកដ្ឋាននីមួយៗដែលមានចែងនៅក្នុងអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប។

សម្រាប់ការតាមដានវឌ្ឍនភាពនៃការអនុវត្ត អ្នកអនុវត្ត នាយកដ្ឋានជំនាញទាំងអស់ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពរបស់ខ្លួនដែលបានអនុវត្ត និងបញ្ជូនមកនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ដើម្បីធ្វើការបូកសរុប និងរៀបចំចងក្រងរបាយការណ៍រួមស្របតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរបស់អាជ្ញាធរទន្លេសាប។

ការអនុវត្តផែនការសកម្មភាពការងារឆ្នាំ ២០២៤ ប្រើប្រាស់ថវិកាជាតិ និងថវិកាពីប្រភពផ្សេងៗ ។ ថវិការបស់អាជ្ញាធរទន្លេសាប ជាថវិកាកម្មវិធីប្រចាំឆ្នាំ ដែលអនុម័តដោយរាជរដ្ឋាភិបាល ចំនួន ៤,៣០០ លានរៀល (បួនពាន់បីរយលានរៀលគត់) និងថវិកាផ្សេងៗទៀតដែលជាទុនបដិភាគ ឬវិភាគទានបន្ថែមបានពីវិស័យឯកជន ដៃគូអភិវឌ្ឍ និងម្ចាស់ជំនួយនានា តាមរយៈការសរសេរគម្រោងស្នើសុំ និងការសិក្សាស្រាវជ្រាវផ្សេងៗ ។

## VI. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប បានបង្កើតជាយន្តការច្បាស់លាស់មួយ ក្នុងការត្រួតពិនិត្យតាមដានរាយការណ៍ និងវាយតម្លៃជាប្រចាំទៅលើការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ក្នុងគោលបំណងដើម្បីធានាឲ្យសម្រេចបានទៅតាមផែនការសកម្មភាពដែលបានដាក់ចេញសម្រាប់អនុវត្ត ។

ការតាមដាន ត្រួតពិនិត្យការអនុវត្ត ថ្នាក់នាយកដ្ឋាន និងការិយាល័យ ត្រូវរៀបចំធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ។

ក្នុងការវាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនសកម្មភាព អគ្គលេខាធិការរងទទួលបន្ទុក ត្រូវដឹកនាំប្រជុំពិនិត្យលើវឌ្ឍនភាពការងារ និងបូកសរុបរបាយការណ៍ លទ្ធផលប្រចាំខែ ។ អគ្គលេខាធិការ នៃអាជ្ញាធរទន្លេសាប ត្រូវដឹកនាំប្រជុំពិនិត្យលើវឌ្ឍភាពការងារ និងបូកសរុបរបាយការណ៍លទ្ធផលប្រចាំត្រីមាស និងឆមាស ។

ការតាមដាន ត្រួតពិនិត្យ វាយតម្លៃលើលទ្ធផលការងារប្រចាំឆ្នាំ ត្រូវធ្វើឡើងដើម្បីដាក់ជូនថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប ។

## VII. សេចក្ដីសន្និដ្ឋាន

ផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាបនេះ ជាផែនទីបង្ហាញផ្លូវដ៏សំខាន់របស់អាជ្ញាធរទន្លេសាប ក្នុងការអនុវត្តបេសកកម្មរបស់ស្ថាប័ន ដើម្បីឈានទៅរួមចំណែកសម្រេចឲ្យបាននូវផែនការយុទ្ធសាស្ត្រ របស់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ ប្រកបដោយភាពជោគជ័យ ។ ផែនការសកម្មភាពនេះជាឧបករណ៍ដ៏សំខាន់ សម្រាប់មន្ត្រីគ្រប់ជាន់ថ្នាក់ ស្ថិតក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប អនុវត្តតាមតួនាទី និងភារកិច្ច ដែលបានកំណត់ក្នុងបទបញ្ញាត្តិជាធរមាន ជាពិសេសការសម្រេចឲ្យបានទៅតាមផែនការយុទ្ធសាស្ត្ររបស់ស្ថាប័ន រយៈពេល ៥ ឆ្នាំ (២០២៤-២០២៨) ។

ការសម្រេចបានដោយជោគជ័យក្នុងការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ តម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែង យកចិត្តទុកដាក់រួមគ្នា និងសហការយ៉ាងជិតស្និទ្ធរវាងនាយកដ្ឋានទាំង ៤ និងការិយាល័យទាំង ១៤ ស្ថិតក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ព្រមទាំងភាគីពាក់ព័ន្ធ ។

## ឧបសម្ព័ន្ធ ១ ៖ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៧០៥

**ស្តីពី**

**ការបង្កើតអាជ្ញាធរទន្លេសាប**

**យើង**

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- ១ -

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្ដីពីការបង្កើត និងគ្រប់គ្រងបរិវេណជីវមណ្ឌលបឹងទន្លេសាប
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតអាជ្ញាធរមួយ សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប មានឈ្មោះថា **អាជ្ញាធរទន្លេសាប** ដែលហៅជាអក្សរកាត់ថា **អ.ទ.ស.** ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

វិសាលភាពនៃតំបន់ទន្លេសាប ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- ២ -

## ជំពូកទី ២

## សមាសភាព

**មាត្រា ៣.-**

**អ.ខ.ស.** មានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| - ឧបនាយករដ្ឋមន្ត្រី ឬ ទេសរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី | | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់មួយចំនួន | | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | សមាជិក |
| - អនុប្រធាន ឬអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ០១រូប | សមាជិក |
| - ប្រធាន ឬអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ០១រូប | សមាជិក |
| - ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | | សមាជិក |
| - អគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | | សមាជិក |
| - អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- ៣ -

- អគ្គនាយកអាជ្ញាធរអប្សរា សមាជិក
- អភិបាលខេត្តកំពង់ឆ្នាំង សមាជិក
- អភិបាលខេត្តពោធិ៍សាត់ សមាជិក
- អភិបាលខេត្តបាត់ដំបង សមាជិក
- អភិបាលខេត្តបន្ទាយមានជ័យ សមាជិក
- អភិបាលខេត្តសៀមរាប សមាជិក
- អភិបាលខេត្តកំពង់ធំ សមាជិក
- អភិបាលខេត្តកំពង់ចាម សមាជិក
- អភិបាលខេត្តកណ្តាល សមាជិក។

សមាសភាពជាក់ស្តែងរបស់ **អ.ទ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី ៣
## ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ អ.ទ.ស.

**មាត្រា ៤.-**

**អ.ទ.ស.** មានតួនាទី ភារកិច្ច សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប ដូចតទៅ៖

- ជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាលលើរាល់គម្រោង ដោយធ្វើការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល

- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗ

- សម្របសម្រួលរាល់សកម្មភាព ដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្ត របស់ក្រសួងស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា ដែលមាននៅក្នុងតំបន់ទន្លេសាប ដើម្បីឱ្យការងារមានភាពរលូនជាមួយគ្នាប្រកបដោយប្រសិទ្ធភាព

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនានា ដើម្បីជំរុញឱ្យប្រតិបត្តិករពាក់ព័ន្ធអនុវត្តស្របតាមយុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាល

- ធ្វើជាតំណាងរាជរដ្ឋាភិបាលក្នុងសកម្មភាពការងាររួមមាន កិច្ចប្រជុំ ការចរចា និងការដោះស្រាយរាល់បញ្ហាដែលអាចកើតមានជាយថាហេតុ

- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ កិច្ចសន្យាទាំងឡាយ ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- ជាសមភាគីជាមួយគ្រប់ដៃគូអភិវឌ្ឍទាំងអស់ក្នុងការរួមគ្នាពិចារណា ដើម្បីកំណត់សកម្មភាពដែលត្រូវអនុវត្ត
- ប្រមូល វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យ ដើម្បីផ្សព្វផ្សាយ និងចែករំលែកដល់អ្នកពាក់ព័ន្ធ
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ
- រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីសកម្មភាពការងារសំខាន់ៗ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា ៥.-**

**អ.ទ.ស.** មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដោយមានការណែនាំ និងចង្អុលទិសពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាព ដូចតទៅ៖

| | |
|---|---|
| - ប្រធាន អ.ទ.ស. | ប្រធាន |
| - អនុប្រធាន អ.ទ.ស. | អនុប្រធាន |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក |
| - អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក។ |

**មាត្រា ៦.-**

**អ.ទ.ស.** ដឹកនាំដោយប្រធានមួយរូប មានឋានៈទាបបំផុតស្មើរដ្ឋមន្ត្រីជាអ្នកទទួលខុសត្រូវរួមចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធាន និងទីប្រឹក្សាមួយចំនួនជាជំនួយការ។

**មាត្រា ៧.-**

**អ.ទ.ស.** មានអគ្គលេខាធិការដ្ឋានមួយ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ការទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាង ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព។

អគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើរដ្ឋលេខាធិការអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។

អគ្គលេខាធិការដ្ឋានត្រូវអនុវត្តការងារទៅតាមការណែនាំរបស់ប្រធាន។

**មាត្រា ៨.-**

ដើម្បីបំពេញការងាររបស់ខ្លួន ជូនរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ **អ.ទ.ស.** ត្រូវមានតំណាងចូលរួមអមដាន និងផ្តល់យោបល់នៅក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងអង្គប្រជុំអន្តរក្រសួងផ្សេងៗ ពាក់ព័ន្ធនឹងកិច្ចការទន្លេសាបដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី ឬដោយក្រសួង ស្ថាប័ននានា។

**អ.ឲ.ស.** មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់នៃក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធនានា ឬឥស្សរជនដែលមានបទពិសោធ និងសមត្ថភាពខ្ពស់ ដើម្បីចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន។

ក្នុងរយៈពេល ៣ (បី) ខែ **អ.ឲ.ស.** ត្រូវកោះប្រជុំសាមញ្ញម្តង។ ក្នុងករណីចាំបាច់ ប្រធាន **អ.ឲ.ស.** ឬគណៈកម្មាធិការប្រតិបត្តិនៃ **អ.ឲ.ស.** អាចកោះប្រជុំវិសាមញ្ញ។ ករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញក្នុងការដឹកនាំកិច្ចប្រជុំតាមការណែនាំរបស់ប្រធាន។

ក្នុងរយៈពេល ១ (មួយ) ខែ គណៈកម្មាធិការប្រតិបត្តិនៃ **អ.ឲ.ស.** ត្រូវប្រជុំសាមញ្ញម្តង។

**មាត្រា ៩.–**

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន **អ.ឲ.ស.** ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១០.–**

**អ.ឲ.ស.** មានសិទ្ធិប្រើត្រាដោយឡែក និងមានទីស្នាក់ការកំណត់ដោយទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១១.–**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ឲ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ៤
## ប្រភពធនធានថវិកា

**មាត្រា ១២.–**

ប្រភពធនធានថវិការបស់ **អ.ឲ.ស.** សម្រាប់បំពេញការងាររបស់ខ្លួន បានមកពី៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល។

**អ.ឲ.ស.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុង ឬក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- ៦ -

ជំពូកទី ៥

អវសានប្បញ្ញត្តិ

**មាត្រា ១៣._**

ព្រះរាជក្រឹត្យនេះជំនួសព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការបង្កើតអាជ្ញាធរអាងទន្លេសាប ដែលត្រូវបាននិរាករណ៍។

**មាត្រា ១៤._**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.០៩០៦.៧៦៤ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៧៤០ ច.ល

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៩**

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

- ៧ -

**ឧបសម្ព័ន្ធ ២ ៖ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ស្តីពីការកែសម្រួល មាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១០/២៥៨

## ស្តីពី

## ការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

១

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្ដីពីការបង្កើត និងគ្រប់គ្រងបម្រុងជីវមណ្ឌលបឹងទន្លេសាប

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីការបង្កើតអាជ្ញាធរទន្លេសាប

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

ត្រូវបានកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីការបង្កើតអាជ្ញាធរទន្លេសាប ដូចតទៅ ៖

**មាត្រា៣ថ្មី.-**

**អ.ទ.ស.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| -ឧបនាយករដ្ឋមន្ត្រី ឬ ទេសរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី | | ប្រធាន |
| -ឥស្សរជនជាន់ខ្ពស់មួយចំនួន | | អនុប្រធាន |
| -ឥស្សរជនជាន់ខ្ពស់ | ០១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១រូប | សមាជិក |

២

| | | |
|---|---|---|
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | សមាជិក |
| -រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| -អនុប្រធាន ឬអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ០១រូប | សមាជិក |
| -ប្រធាន ឬអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ០១រូប | សមាជិក |
| -តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | | សមាជិក |
| -អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | | សមាជិក |
| -អគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | | សមាជិក |
| -អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | | សមាជិក |
| -អគ្គនាយកអាជ្ញាធរអប្សរា | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកណ្តាល | | សមាជិក |

-សមាសភាពជាក់ស្តែងរបស់ **អ.ខ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

៣

**មាត្រា៥ថ្មី.-**

**អ.ទ.ស.** មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| -ប្រធាន អ.ទ.ស. | ប្រធាន |
| -អនុប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ អ.ទ.ស. | អនុប្រធាន |
| -អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក |
| -អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក ។ |

**មាត្រា៦ថ្មី.-**

**អ.ទ.ស.** ដឹកនាំដោយប្រធានមួយរូប ជាអ្នកទទួលខុសត្រូវរួមចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ ព្រមទាំងទីប្រឹក្សាមួយចំនួនជាជំនួយការ ។

**មាត្រា៩ថ្មី.-**

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ជាបន្ទុករបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា១០ថ្មី.-**

**អ.ទ.ស.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន ។

**មាត្រា១២ថ្មី.-**

ប្រភពធនធានថវិការបស់ **អ.ទ.ស.** សម្រាប់បំពេញការងាររបស់ខ្លួន បានមកពី ៖

-ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំ របស់ក្រសួងធនធានទឹក និងឧតុនិយម

-អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា

-ជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល ។

**អ.ទ.ស.**មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុងប្រទេស និងក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព ។

មាត្រា៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១០

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

៣/ល.១០០៣.២៦១

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខៈ ២៥២ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**យុន ឌិនកេន**

៥

5/5

# ឧបសម្ព័ន្ធ ៣ ៖ អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការ នៃអាជ្ញាធរទន្លេសាប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៦ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ

## របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៦០៩ / ៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្ដីពីការបង្កើតអាជ្ញាធរទន្លេសាប
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរទន្លេសាប

### សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ( **អ.ទ.ស** ) ។

## ជំពូកទី ២
## តួនាទី និង ភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ( **អ.ទ.ស** ) មានតួនាទី និង ភារកិច្ច ដូចតទៅ :

- ទទួលបន្ទុកដឹកនាំ ចាត់ចែង និងសម្របសម្រួល រាល់សកម្មភាពការងារ ប្រចាំថ្ងៃរបស់ **អ.ទ.ស**
- សិក្សាស្រាវជ្រាវ អំពីសក្តានុពលធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដាន លើការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ និងធ្វើវិភាគនូវរាល់ព័ត៌មាន និងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ ចំពោះមុខ និងយូរអង្វែង ជូនរាជរដ្ឋាភិបាល ក្នុងការកំណត់ទីតាំងគោលដៅបម្រើដល់កិច្ចអភិវឌ្ឍន៍ និងអភិរក្ស
- រៀបចំគោលនយោបាយ ទស្សនវិស័យ បេសកកម្មរបស់អាជ្ញាធរទន្លេសាប
- សម្របសម្រួល និងសហការ ជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពទាក់ទងនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ ក្នុងតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព
- សហការ ជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោងអភិរក្ស អភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុងតំបន់ទន្លេសាប
- រៀបចំចងក្រងឯកសារទិន្នន័យ ព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនប្រធាន **អ.ទ.ស**
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាន **អ.ទ.ស** ប្រគល់ជូន ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ និង ការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ( **អ.ទ.ស** ) មានរចនាសម្ព័ន្ធ ដូចខាងក្រោម :

១- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

២- នាយកដ្ឋានធនធានធម្មជាតិ

៣- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស

៤- នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ។

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

**មាត្រា ៤.-**

នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តការ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ទទួលខុសត្រូវលើសេវាកម្មរដ្ឋបាលទូទៅ និងសម្របសម្រួលការងាររដ្ឋបាល ជូនគ្រប់អង្គភាពនៅក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស**
- ទទួលខុសត្រូវលើការងារសំណុំលិខិត ឯកសារ លិខិតបទដ្ឋានគតិយុត្តិ ឯកសារសម្ងាត់ ការងារតម្កល់ឯកសារ ពិធីការ សណ្តាប់ធ្នាប់ និងអនាម័យ
- គ្រប់គ្រងឯកសារ និងក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិក និងរៀបចំប្រវត្តិ ប្រាក់ឧបត្ថម្ភផ្សេងៗ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌ របស់ **អ.ទ.ស**
- រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្ស
- រៀបចំគម្រោងផែនការថវិកា សម្ភារៈ និងមធ្យោបាយនានា របស់ **អ.ទ.ស**
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាព រយៈពេលខ្លី មធ្យម និងវែង សម្រាប់បម្រើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព
- តាមដាន វាយតម្លៃ ប្រសិទ្ធិភាពនៃការអនុវត្តផែនការសកម្មភាព
- សម្របសម្រួល សហការ ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីគៀងគររកជំនួយ
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៥.-**

នាយកដ្ឋានធនធានធម្មជាតិ មានតួនាទី និងភារកិច្ច ដូចតទៅ :

- សិក្សាស្រាវជ្រាវពីសក្តានុពលទឹក និងការប្រែប្រួលអាកាសធាតុ ព្រមទាំងកត្តាផ្សេងៗទៀត ដែលនាំឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីធនធានមច្ឆជាតិ ធនធានព្រៃលិចទឹក ធនធានរ៉ែ និងធនធានជីវចម្រុះផ្សេងៗទៀត ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីសក្តានុពលទឹក-ដី ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ពិនិត្យ និងផ្តល់យោបល់ លើការស្នើសុំប្រើប្រាស់នូវរាល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៦.-**

នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស មានតួនាទី និងភារកិច្ច ដូចតទៅ :

- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ លើការធ្វើអាជីវកម្មធនធានទឹក-ដី ធនធានមច្ឆជាតិ ធនធានរ៉ែ ធនធានជីវចម្រុះផ្សេងៗទៀត ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ លើការប្រើប្រាស់រាល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ ព័ត៌មាន វិភាគ ដើម្បីកំណត់តំបន់អភិរក្សធនធានទឹក ធនធានព្រៃលិចទឹក ធនធានមច្ឆជាតិ ធនធានរ៉ែ និងធនធានជីវចម្រុះផ្សេងៗទៀត ដើម្បីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំផែនទី សម្រាប់បម្រើដល់ការគ្រប់គ្រង ការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៧.-**

នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ មានតួនាទី និងភារកិច្ច ដូចតទៅ :

- ប្រមូលចងក្រង និងសិក្សាស្វែងយល់នូវរាល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលមានការពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹង និងសម្រុះសម្រួលនូវរាល់វិវាទនានា ដែលកើតមានឡើងក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ចូលរួមផ្តល់យោបល់ លើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ដែលមានការពាក់ព័ន្ធ
- រៀបចំពិធីសារ អនុស្សរណៈ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ
- ផ្សព្វផ្សាយព័ត៌មាន ទាំងវិជ្ជមាន ទាំងអវិជ្ជមាន សំដៅបម្រើឱ្យកិច្ចអភិរក្ស និងអភិវឌ្ឍន៍ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- សហការ ជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **អ.ទ.ស** ប្រគល់ជូន ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** មានមន្ត្រីបម្រើការងារ មកពីក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** អាចមានអ្នកជំនាញការ ឬបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងាររបស់ខ្លួន ។

ការបែងចែកលំអិត អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃ **អ.ទ.ស** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ទ.ស** ។

**មាត្រា ៩.-**

ការរៀបចំ និងការប្រព្រឹត្តទៅ របស់បណ្តានាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន នៃ **អ.ឌ.ស** ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន **អ.ឌ.ស** ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ ៤ ៖ ប្រកាសលេខ ០២៥ អទស ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ការិយាល័យចំណុះបណ្តានាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរទន្លេសាប**

លេខ :....០២៥.....អទស

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០០៩

**ប្រកាស**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តិទៅ របស់ការិយាល័យចំណុះបណ្តានាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប**

**ប្រធានអាជ្ញាធរទន្លេសាប**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញសេចក្តីសម្រេចលេខ ៤១ សសរ ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពី ការតែងតាំងសមាសភាពរបស់អាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប

**ស ម្រេ ច**

**ប្រការ ១.**

ត្រូវបានកំណត់អំពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់បណ្តានាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប រួមមាន :

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ
- នាយកដ្ឋានធនធានធម្មជាតិ
- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស
- នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ។



អគារលេខ: ៣៦៤,មហាវិថី ព្រះមុនីវង្ស,សង្កាត់ ផ្សារដើមថ្កូវ,ខណ្ឌ ចំការមន,រាជធានីភ្នំពេញ, ទូរស័ព្ទ /ទូរសារលេខ: ០២៣ ៧២៧ ៤៥៤,

**ប្រការ ២.**

នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ មានរចនាសម្ព័ន្ធ ដូចខាងក្រោម :

ក- ការិយាល័យរដ្ឋបាល

ខ- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

គ- ការិយាល័យផែនការ និងសហប្រតិបត្តិការ

ឃ- ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ក-ការិយាល័យរដ្ឋបាល** មានភារកិច្ច :

- ផ្តល់សេវាកម្មរដ្ឋបាល និងសម្របសម្រួលការងាររដ្ឋបាលក្នុងអគ្គលេខាធិការដ្ឋាននៃ អ.ទ.ស
- រៀបចំតាក់តែងលិខិតរដ្ឋបាល ទទួលចុះលេខលិខិតចេញ-ចូល និងបែងចែកឯកសារ
- គ្រប់គ្រងរាល់សំណុំលិខិត ឯកសារ លិខិតបទដ្ឋានគតិយុត្តិ និងឯកសារសម្ងាត់នានា
- សម្របសម្រួលរៀបចំចាត់ចែងកិច្ចប្រជុំនានារបស់ អ.ទ.ស
- គ្រប់គ្រងបណ្តាញទំនាក់ទំនង ទឹក-ភ្លើង សណ្តាប់ធ្នាប់ និងអនាម័យក្នុងអគ្គលេខាធិការដ្ឋាននៃ អ.ទ.ស
- រៀបចំរបាយការណ៍បូកសរុបសកម្មភាពការងាររបស់នាយកដ្ឋាន
- បំពេញការងារចាំបាច់តាមការណែនាំពីប្រធាននាយកដ្ឋាន ឬអគ្គលេខាធិការ អ.ទ.ស
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ខ- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ** មានភារកិច្ច :

- រៀបចំគម្រោងផែនការថវិកា សម្ភារៈ និងមធ្យោបាយនានារបស់ អ.ទ.ស
- គ្រប់គ្រង និងរៀបចំបញ្ជីចំណូល និងចំណាយ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌ
- រៀបចំឯកសារលទ្ធកម្ម និងផ្គត់ផ្គង់សម្ភារៈការិយាល័យ និងបរិក្ខាចាំបាច់សម្រាប់ដំណើរការការងារក្នុង អ.ទ.ស
- រៀបចំ និងដោះស្រាយប្រាក់បេសកកម្មសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី អ.ទ.ស
- ទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋានលើរាល់បែបបទប្រើប្រាស់ថវិកា
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**គ- ការិយាល័យផែនការ និងសហប្រតិបត្តិការ** មានភារកិច្ច :

- សិក្សា និងប្រមូលចងក្រងឯកសារគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធ
- ប្រមូល និងចងក្រងគម្រោងអភិវឌ្ឍន៍នានាដែលបានបញ្ចប់ និងកំពុងដំណើការ ព្រមទាំងគម្រោងជាប់កិច្ចសន្យា ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាព រយៈពេលខ្លី មធ្យម និងវែង សម្រាប់បម្រើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ប្រកបដោយនិរន្តរភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្តគម្រោងផែនការសកម្មភាព គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សម្របសម្រួល និងជម្រុញកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីគៀងគររកជំនួយ សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ឃ- ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល** មានភារកិច្ច :

- គ្រប់គ្រងឯកសារ ក្របខ័ណ្ឌ និងរៀបចំប្រវត្តិរបស់មន្ត្រីរាជការ
- រៀបចំឯកសារចាត់តាំង និងតែងតាំងមន្ត្រីរាជការក្នុង អ.ទ.ស
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាព និងសមត្ថភាពការងាររបស់មន្ត្រីរាជការ
- រៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់អភិវឌ្ឍន៍ធនធានមនុស្សក្នុង អ.ទ.ស
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ប្រការ ៣.-**

នាយកដ្ឋានធនធានធម្មជាតិ មានរចនាសម្ព័ន្ធដូចខាងក្រោម :

ក-ការិយាល័យធនធានទឹក

ខ-ការិយាល័យធនធានរ៉ែ

គ-ការិយាល័យជីវចម្រុះ

ឃ-ការិយាល័យកសិកម្មចម្រុះ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ក- ការិយាល័យធនធានទឹក** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីសក្ដានុពលធនធានទឹកក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ ព្រមទាំងកត្តាផ្សេងៗទៀត ដែលនាំឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សា និងកំណត់តំបន់អភិរក្ស និងអភិវឌ្ឍធនធានទឹក
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ធនធានទឹក ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និងអនុសាសន៍ផ្សេងៗ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ខ- ការិយាល័យធនធានរ៉ែ** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីសក្ដានុពលធនធានរ៉ែក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានរ៉ែ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពរុករករ៉ែគ្រប់ប្រភេទ ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និង អនុសាសន៍ផ្សេងៗ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**គ- ការិយាល័យជីវចម្រុះ** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីធនធានមច្ឆជាតិ ធនធានព្រៃលិចទឹក និងធនធានជីវចម្រុះផ្សេងៗទៀត ដើម្បីបង្កើតឡើងនូវផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ ប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាព
- សិក្សាស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យប៉ះពាល់ដល់ជីវចម្រុះ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រែប្រួលធនធានមច្ឆជាតិ និងព្រៃលិចទឹក ដែលបណ្ដាលមកពីកត្តាធម្មជាតិ និងកត្តាមនុស្ស ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និងអនុសាសន៍ផ្សេងៗ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងជីវចម្រុះ
- រាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ឃ- ការិយាល័យកសិកម្មចម្រុះ** មានភារកិច្ច :

- សិក្សាស្រាវជ្រាវអំពីសក្តានុពលទឹក-ដី សម្រាប់បម្រើឱ្យវិស័យកសិកម្ម
- ប្រមូល និងរៀបចំព័ត៌មានស្តីពីការប្រើប្រាស់ដី
- កំណត់តំបន់អភិវឌ្ឍវិស័យកសិកម្ម
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ទឹក-ដី កសិកម្ម ដើម្បីបង្កើតឡើងនូវវិធានការ បទដ្ឋាន និងអនុសាសន៍ផ្សេងៗ
- លើកគម្រោងរាល់ការស្នើសុំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកសិកម្មចម្រុះ
- វាយការណ៍ជាប្រចាំជូនប្រធាននាយកដ្ឋានអំពីសកម្មភាពការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន ឬតាមការចង្អុលណែនាំពីអគ្គលេខាធិការ អ.ទ.ស ។

**ប្រការ ៥.-**

